មេរៀនទី ១៧ - តាបារ៉ (تبرأ) ....... ៧៥
លំហាត់ ១ ....... ៧៧
លំហាត់ ២ ....... ៨២
លំហាត់ ៣ ....... ៨៣
លំហាត់ ៤ ....... ៨៥
លំហាត់ ៥ ....... ៨៦
លំហាត់ ៦ ....... ៨៧
លំហាត់ ៧ ....... ៨៨
លំហាត់ ៨ ....... ៨៩
លំហាត់ ៩ ....... ៩០
លំហាត់ ១០ ....... ៩៣

# مدرسة اهل البيت

# សាលា អាស្ហ់លុល-បៃត៍

## សៀវភៅ ហ្វីក្ហេះហ្ហ៍ ថ្នាក់ទី ៧

(អាយុ ១១-១២ ឆ្នាំ)

រ៉ស្ហូលុលឡោះហ្ហ៍ ﷺ មានព្រះវចនៈថា៖ "ការស្វែងរកចំណេះវិជ្ជា ជាកាតព្វកិច្ចរបស់មុស្លីមីនប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ - ស្វ៉ឡាត្ញ់ - សាច្ញ់ដ្ញាស្ញ់(១)..........................៥

មេរៀនទី ២ - ស្វ៉ឡាត្ញ់ - សាច្ញ់ដ្ញាស្ញ់(២)......................... ១០

មេរៀនទី ៣ - ស្វ៉ឡាត្ញ់ - សាច្ញ់ដ្ញាស្ញ់ (៣) ...................... ១៤

មេរៀនទី ៤ - ស្វ៉ឡាត្ញ់ - តាស្ហាស្ញ់ហ្វ៊ូដ្ញ និង សាឡាម..... ១៨

មេរៀនទី ៥ - ស្វ៉ឡាត្ញ់ - តារទិប, មូវ៉ាឡាត់ និង តាក៉ុគ្វីបាត់
.............................................................................២៤

មេរៀនទី ៦ - ស្វ៉ឡាត្ញ់ - មូណាហ្វីយ៉ាត់ក្នុងស្វ៉ឡាត្ញ់.......២៨

មេរៀនទី ៧ - ស្វ៉ឡាត្ញ់ - ម៉ាសាអ៊ីល (مسائل បញ្ហា) នានា (១)
.............................................................................៣៣

មេរៀនទី ៨ - ស្វ៉ឡាត្ញ់ - ម៉ាសាអ៊ីល(ច្បាប់)នានា(២)..... ៣៨

មេរៀនទី ៩ - ស្វ៉ឡាត្ញ់ - កន្លែងស្វ៉ឡាត្ញ់......................... ៤៤

មេរៀនទី ១០ - ស្វ៉ឡាត្ញ់ - សំលៀកបំពាក់សម្រាប់ស្វ៉ឡាត្ញ់
............................................................................. ៤៨

មេរៀនទី ១១ - ស្វ៉ឡាត្ញ់ - ពេលវេលាស្វ៉ឡាត្ញ់ .............. ៥៤

មេរៀនទី ១២ - ស្វ៉ាំម៍(១) ........................................... ៥៨

មេរៀនទី ១៣ - ស្វ៉ាំម៍(២)............................................ ៦១

មេរៀនទី ១៤ - អាំរ៍ ប៊ិល-ម៉ាក៉្រូហ្វ (امر بالمعروف)............ ៦៦

មេរៀនទី ១៥ - ណាហ្ញី អ៊ុានិល មុនការ (نهى عن المنكر).... ៦៩

មេរៀនទី ១៦ - តាវ៉ាល់ឡា (تولّى) ................................ ៧២

គ) ធ្វើសាច់ដាស់ដោយបិទត្របកភ្នែក ។

ប្រសិនបើមិនអាចធ្វើកាយវិការទាំងនេះបានទេ ត្រូវធ្វើសាច់ដាស់ដោយកាយវិការដៃ ឬ ដោយប៉ែករូបកាយមួយផ្សេងទៀត ។

២. ប្រសិនបើមានរបួសលើថ្ងាស មិនអាចដាក់ថ្ងាសលើដីបានទេ ឲ្យធ្វើសាច់ដាស់ជាមួយប៉ែកមួយទៀតរបស់ថ្ងាស ។ ប្រសិនបើមានរបួសពេញថ្ងាសតែម្ដង ឲ្យធ្វើសាច់ដាស់ជាមួយចិញ្ចើម ។

៣. ប្រសិនបើអ្នកណាភ្លេចធ្វើសាច់ដាស់ ហើយនឹកឃើញវិញមុនធ្វើរុគុអ៍ខាងមុខ ឲ្យអ្នកនោះអង្គុយចុះវិញហើយធ្វើសាច់ដាស់ រួចហើយបំពេញស្វ៍ឡាត់បន្ត ។ តែបើនឹកឃើញវិញក្រោយពីបានរុគុអ៍ហើយ ស្វ៍ឡាត់អ្នកនោះត្រូវមោឃៈ ។

៤. ប្រសិនបើអ្នកណាដាក់ថ្ងាសលើអ្វីមួយ ដែលច្បាប់បានហាមធ្វើសាច់ដាស់លើ ឲ្យអ្នកនោះលើកថ្ងាសទៅដាក់លើអ្វីមួយដែលច្បាប់អនុញ្ញាត ។



**មេរៀនទី ១**

# ស្វ៍ឡាត់ - អធិប្បាយលំអិតអំពី ទង្វើវ៉ាយីបក្នុងស្វ៍ឡាត់

## សាច់ដាស់

សាច់ដាស់ពីរក្នុងរ៉ក់អាត់នីមួយៗ ជាវ៉ាយីបរបស់ស្វ៍ឡាត់ ។ សាច់ដាស់ទាំងពីររួមជា វ៉ាយីប រុកន៍ (រុកុនវ៉ាយីប) ក្នុង ស្វ៍ឡាត់ ។ បើភ្លេចសាច់ដាស់ទាំងពីរ ឬបើថែម សាច់ដាស់ពីរ ទោះបីដោយចេតនាក្ដី ដោយអចេតនាក្ដី ស្វ៍ឡាត់ត្រូវមោឃៈ (បាទិល) ។

តែបើភ្លេចសាច់ដាស់មួយ ឬបើថែមសាច់ដាស់មួយដោយភ្លាំងភ្លាត់ ស្វ៍ឡាត់នៅតែត្រឹមត្រូវ ។ ប្រាកដណាស់ បើថែម ឬកាត់បន្ថយសាច់ដាស់មួយដោយចេតនា ស្វ៍ឡាត់ត្រូវមោឃៈ ។

ប្រាំមួយប្រការវ៉ាយីបក្នុងសាច់ដាស់៖

១. ក្នុងពេលសាច់ដ្ចាស់ ប្រាំពីរប៉ែករបស់រូបកាយចាំបាច់ត្រូវប៉ះដី (កម្រាល) ។ ប៉ែករូបកាយនោះគឺ៖ ថ្ងាស, បាតដៃទាំងពីរ, ជង្គង់ទាំងពីរ, មេជើងរបស់ជើង ទាំងពីរ ។ ក្នុងចំណោមប៉ែកទាំងប្រាំពីរនេះ ចាំបាច់ត្រូវដាក់ថ្ងាសផ្ទាល់ដី ។

២. ស្ទ៊ីករ៍ (ការសូត្រ) ក៏ជាវ៉ាយ៊ីបរបស់សាច់ដ្ចាស់ដែរ ។ ស្ទ៊ីកររបស់សាច់ដ្ចាស់ ស្រដៀងស្ទ៊ីករ៍រូគុអ៍ដែរ ខុសគ្នាតែមួយពាក្យទេ ។ គឺសូត្រដូចតទៅគឺ៖ "ស៊ុបហ្ចាណា រ៉ប់ប៊ីយ៉ាល់ អាក់ឡា វ៉ា ប៊ីហ្ចាំឌ្និះហ្ច៍ (سُبْحَانَ رَبِّيَ الْاَعْلٰى وَ بِحَمْدِهِ)

៣. ត្រូវឲ្យនឹងខ្លួនក្នុងពេលសូត្រស្ទ៊ីករ៍ ។

៤. ប៉ែករូបកាយទាំងប្រាំពីរប៉ែកចាំបាច់ ត្រូវប៉ះដី (កម្រាល) ក្នុងពេលសូត្រ ។ ប្រសិនបើអ្នកចាំបាច់ត្រូវលើកប៉ែកណាមួយពីដី អ្នកត្រូវស្ងាត់មាត់ (គឺឈប់សូត្រសិន) ក្រោយមកបានដាក់ប៉ែកនោះមកលើដីវិញ ទើបអ្នកសូត្រតទៀត ។



៥. បន្ទាប់ពីសាច់ដ្ចាស់ទីមួយ ត្រូវងើបមកអង្គុយ ។

៦. កន្លែងដែលគេដាក់ថ្ងាសនិងជើង ត្រូវឲ្យស្មើគ្នា ។ ប្រសិនបើមានកម្ពស់ខុសគ្នា ឲ្យខុសគ្នាតិចជាង ១០ សង់ទីម៉ែត្រ ។

## សាច់ដ្ចាស់ជាប៉ែកមួយដែលថ្លៃថ្នូរជាងគេរបស់ស្ទ្រឡាត់

## ច្បាប់ (ហ៊ូកុម) ផ្សេងទៀតពាក់ព័ន្ធនឹងសាច់ដ្ចាស់

១. បើអ្នកណាមិនអាចធ្វើសាច់ដ្ចាស់ ឲ្យបានត្រឹមត្រូវទេ ដោយសារមានជម្ងឺ ឬ ដោយសារមូលហេតុផ្សេងទៀត ឲ្យអ្នកនោះធ្វើដូចតទៅនេះ (គប្បីធ្វើតាមលំដាប់) គឺ៖

ក) ព្យាយាមបង្អោនខ្លួនតាមសមត្ថភាពដែលអាចធ្វើទៅបាន ហើយលើកដុំដី ម៉ុស្ហ៍ (مهر) ឬទូរបាស់ (تربة) មករកថ្ងាស ។

ខ) ធ្វើសាច់ដ្ចាស់ដោយឱនក្បាល ។

១២. ក្រោយពីបានងើបពីសាច់ដ្វាស់ទីមួយ មុសតាហ្ពាប់ឲ្យសូត្រតាក់បៀរ ហើយសូត្រថា "អាស់តាក់ហ្វី-រុលឡោះហ្វ៍ រ៉ប់ប៊ី វ៉ា អាទូប៊ូ អ៊ីឡៃហ៊្វី (أَسْتَغْفِرُ ٱللَّهَ رَبِّي وَأَتُوبُ إِلَيْهِ)" រួចហើយថាតាក់បៀរមុនចុះសាច់ដ្វាស់លើកទីពីរ ។

១៣. ថាតាក់បៀរក្រោយសាច់ដ្វាស់លើកទីពីរ ។

១៤. សូត្រស្វ៍ឡាវ៉ាតក្នុងសាច់ដ្វាស់ ។

១៥. ដើម្បីក្រោកឡើងបំពេញរ៉ក់អាត់បន្ត បុរសគប្បីលើកជង្គង់មុន បន្ទាប់មក ប្រអប់ដៃ។ រីឯនារីគប្បីដាក់ប្រអប់ដៃលើភ្លៅហើយងើបឡើង ។

**ម៉ាក់រុះហ្វ៍**

១. អង្គុយលើកែងជើងក្នុងចន្លោះសាច់ដ្វាស់ទាំងពីរ និងក្រោយពីនោះ (ដោយចុចលើម្រាមជើង) ។

២. ដាក់ដៃលើដី (ពោលគឺប្រអប់ដៃដល់កែងដៃ) ។

៣. សូត្រគួរអានក្នុងសាច់ដ្វាស់ ។



៥. ប្រសិនបើអ្នកណាដាក់ថ្ងាសលើកន្លែង ដែលមានកម្ពស់លើសពី ១០ សង់ទីម៉ែត្រ ប្រៀបធៀបនឹងកន្លែងដាក់ជើង ឲ្យអ្នកនោះលើកក្បាលដើម្បីកែឲ្យកម្ពស់ទាបជាង ១០ សង់ទីម៉ែត្រ ។

៦. អ៊ីស្លាមហាមដាច់ខាតធ្វើសាច់ដ្វាស់ ដាក់អ្នកណាផ្សេងពីអល់ឡោះហ្វ៍ عز وجل ។ អ្នកខ្លះដាក់ថ្ងាសលើមាត់ទ្វារមតក(មៈតៈកៈ)ចេតិយរបស់អ៊ីម៉ាំពិសិដ្ឋ عليهم السلام ប្រសិនបើសាច់ដ្វាស់នេះជាសាច់ដ្វាស់ ស្ហ៊ុករ៍ ចំពោះអល់ឡោះហ្វ៍ عز وجل វាជាទង្វើត្រឹមត្រូវ ពុំនោះទេវាជាទង្វើហ្ពារ៉ាំ ។

**សាច់ដ្វាស់ជាមិរ៉ាជរបស់អ្នកមានសទ្ធា**

## មេរៀនទី ២

# ស្ហ៏ឡាត្ហ៍ - អធិប្បាយលំអិតអំពី ទង្វើវ៉ាយ៊ីបក្នុងស្ហ៏ឡាត្ហ៍

**សាច់ដ្ហាស្ហ់**

ប្រការ**មុសតាហ្ហាប់** និង ប្រការ**ម៉ាក់រ៉ុះហ្ហ៍**ក្នុងសាច់ដ្ហាស្ហ់ ។

**មុសតាហ្ហាប់ (ស៊ូណាត្ហ់)**

១. ថាតាក់បៀរមុនសាច់ដ្ហាស្ហ់ ពោលគឺ ក្រោយពីថា "សាមីអ៊ុល់ឡ៍ហ្វ្ហ លីម៉ាន់ ហ្ហាមីដ្ហាស្ហ់" ហើយលើកដៃឡើងពេលថាតាក់បៀរ ។

២. ពេលចុះសាច់ដ្ហាស្ហ់ បុរសគប្បីដាក់ប្រអប់ដៃមុនសិន បន្ទាប់មកទើបដាក់ក្បាលជង្គង់ ។ រីឯនារីវិញ គប្បីដាក់ក្បាលជង្គង់មុនដាក់ប្រអប់ដៃ ។

៣. ដាក់ថ្ងាសទៅលើដីឲ្យស៊ប់ ។



៤. ដាក់ក្បាលទាល់តែច្រមុះកកិតដី ។

៥. បុរសគប្បីបន្ទែកដៃពីខ្លួនបន្តិច ។ រីឯនារីគប្បីដាក់ដៃប្របខ្លួន ។ មុសតាហ្ហាប់ឲ្យដាក់ប្រអប់ដៃស្មើត្រចៀក ម្រាមជៀតគ្នា តម្រង់ទៅរកគ៊្ហីបឡាត្ហ់ ។

៦. សម្លឹងមើលទៅឯច្រមុះ ។

៧. សូត្រស៊្ហីករ៍សាច់ដ្ហាស្ហ់ផ្ទួនគ្នា លើសពីមួយដង ជាចំនួនសេស (បី, ប្រាំ ឬ ប្រាំពីរ) ។

៨. ដាក់ថ្ងាសលើដី ។

៩. នៅលើផ្ទៃដីស្មើពីក្បាលដល់ចុងជើង ។

១០. អង្គុយក្នុងចន្លោះសាច់ដ្ហាស្ហ់ទាំងពីរ ។ ក្រោយសាច់ដ្ហាស្ហ់ទីពីរអង្គុយ ដាក់ប្រអប់ជើងឆ្វេងនៅខាងក្រោម ដាក់ខ្នងជើងស្តាំលើបាតជើងឆ្វេង ។

១១. អង្គុយក្នុងចន្លោះសាច់ដ្ហាស្ហ់ទាំងពីរ ។ ដាក់ប្រអប់ដៃលើភ្លៅ ។

ហ្វូសែន៍صلوات الله عليه والسلامនៅការបាឡា" ។ គេស្គាល់ដីនេះជាដី "ទូរបាទុល ហ្វូសៃនីយ៉ាស្ហ៍" ។ ដីនេះជាដីពិសិដ្ឋ ព្រោះវាផ្ទុកនូវលោហិតរបស់អស់បុគ្គល ដែលបានពលីជីវិតនៅឯដែនដីការបាឡា ។

កាលពីសម័យរ៉ស៊ូលុលឡោះហ៍ﷺ បុត្រីព្រះអង្គ ប៊ីប៊ីហ្វាទីម៉ាស្ហ៍سلام الله عليهاបានធ្វើ តាស់ប៊ិះហ្វ៍(تسبيح)ពីដីផ្នូររបស់ហ្ជាដ៉្ហះព៉េះត្ហ៍(حضرة)ហ្ជាំស្ហាស្ហ៍ ប៊ិន អាប់ឌុល មុត្តត៍លិប ។ ហ្ជាដ៉្ហះព៉េះត្ហ៍ហ្ជាំស្ហាស្ហ៍ជាអគ្គប្រមុខរបស់បុគ្គល ដែលបានពលីជីវិតក្នុងសម័យនោះ ។

បើគេប្រើដុំម៉ុស្ហ៍សម្រាប់សាច់ដ្ហាស្ហ៍ កុំឲ្យដុំម៉ុស្ហ៍នោះតូចជាងមេដៃ ។

សាច់ដ្ហាស្ហ៍លើភក់ ឬដីខ្សាច់មិនអាចយកជាការបានទេ ព្រោះថ្ងាសមិននឹងមាំមួន ។

បើមិនមានវត្ថុ ដែលគេអនុញ្ញាតឲ្យសាច់ដ្ហាស្ហ៍លើបាននោះទេ គេអាចសាច់ដ្ហាស្ហ៍លើសំលៀកបំពាក់ខ្លួនឯងបាន ។ បើនៅតែមិនមានលទ្ធភាពទៀត គេអាចសាច់ដ្ហាស្ហ៍លើខ្នងដៃបាន ។ គេអាចយកច្បាប់នេះទៅប្រើបាន បើគេមិនអាចដាក់ថ្ងាសបានលើវត្ថុអនុញ្ញាតសម្រាប់សាច់ដ្ហាស្ហ៍ (ដោយមូលហេតុជម្ងឺ ។ល ។) ។



## ទង្វើមុសតាហ្ហាប់ក្នុងសាច់ដ្ហាស្ហ៍សម្រាប់នារីស្ថិតនៅលើភាពរាបសារម្យទមនិងព្រហ្មចរិយភាព

## មេរៀនទី ៣

# ស្ទ័ឡាត់ - អធិប្បាយលំអិតអំពីទង្វើរ៉ាយ៉ីបក្នុងស្ទ័ឡាត់

### សាច់ដុំង្ហាស់

### វត្ថុដែលអាចសាច់ដុំង្ហាស់លើបាន

១. វត្ថុដែលអ្នកត្រូវដាក់ថ្ងាសលើចាំបាច់ជាវត្ថុ ខាងក្រោមនេះគឺ៖

ក) ដីធម្មជាតិ ។

ខ) អ្វីៗដែលដុះពីក្នុងដី ដោយមានលក្ខខណ្ឌថាមិនអាចយកមកប្រើជាអាហារបាន ឬយកមកធ្វើជាក្រណាត់សំពត់បាន ។

គ) អ្វីៗដែលធ្វើអំពីដីសុទ្ធ ឬអំពីវត្ថុដែលដុះពីដី (ដោយមានលក្ខខណ្ឌដូចខាងលើ) ។

២. "ដី" គឺចង់និយាយថាអ្វីដែលគេស្គាល់ថាជាដីធម្មតា ។



មិនរាប់បញ្ចូលរ៉ែ ឬ ត្បូង ពេជ្រ ដែលមានតម្លៃដែលយកមកពីអណ្តូងរ៉ែនោះទេ ពីព្រោះវាមិនមែនដី ហើយក៏មិនដុះមកពីដីទេ ។

៣. ដូចបានថែងនៅខាងលើហើយ គេមិនអាចសាច់ដុំង្ហាស់លើវត្ថុប្រើជាគ្រឿងបរិភោគ ឬជាក្រណាត់សំពត់បានទេ ។ ដូច្នេះគេសាច់ដុំង្ហាស់លើស្លឹកស្វាយបានតែមិនអាចសាច់ដុំង្ហាស់លើផ្លែស្វាយបានទេ ។ វត្ថុទីមួយជាវត្ថុដែលមិនអាចហូបបាន ឯវត្ថុទីពីរជាផ្លែឈើឆ្ងាញ់ពិសាមួយ ។

៤. គេអាចសាច់ដុំង្ហាស់លើវត្ថុទាំងអស់បាន ដែលធ្វើអំពីដីសុទ្ធដូចជា "មុស្ហរ៍" ដែលស្ទីអ្ហស់ប្រើក្នុងស្ទ័ឡាត់ ។

៥. គេអាចសាច់ដុំង្ហាស់លើសន្លឹកក្រដាសទទេ ឬកំណាត់ឈើបានព្រោះវាចេញមក ពីដើមឈើដែលដុះមកពីដី ។ គេអាចសាច់ដុំង្ហាស់លើសន្លឹកក្រដាសមានសំណេរបានដែរ ឲ្យតែសំណេរនោះជាទឹកមឹក (ជ្រាបទៅក្នុងសាច់ក្រដាស់) ហើយមិនមែនទឹកមឹកដែលបង្កជារបាំងរាំងលើសន្លឹកក្រដាសនោះទេ ។

៦. តែវត្ថុសំណព្វសម្រាប់សាច់ដុំង្ហាស់គឺ "ហ្វារម អ៊ីម៉ាំ

**តាស្ហាស្ហ៊ូដ(២)**

ទង្វើខាងក្រោមនេះជាមុសតាហ្ហាប់ក្នុងតាស្ហាស្ហ៊ូដ ។

**មុសតាហ្ហាប់**

១. ថា "អាល់ហ្ហាំឌូ លិលឡាស្ហ៍" (សូមថ្វាយសេចក្តីសរសើរចំពោះអល់ឡោះហ្ 3) ឬ ថា "ប៊ិសមិលឡាហ្ហ៊ី វ៉ាប៊ិលឡាហ្ហ៊ី វាល់-ហ្ហាំឌូ លិលឡាស្ហ៍ វ៉ា ខយ់រុល អាស់ម៉ាអុី លិលឡាស្ហ៍(بسم الله وبالله و□لحمد لله وخير□لاسماء لله ដោយព្រះនាមអល់ឡោះហ្វ៍ ដោយអាស្រ័យលើអល់ឡោះហ្វ៍ សូមថ្វាយសេចក្តីសរសើរចំពោះអល់ឡោះហ្វ៍ ព្រះនាមដ៏ឧត្តុង្គឧត្តមជាព្រះកម្មសិទ្ធិរបស់ព្រះអង្គ) មុនចាប់ផ្តើមសូត្រតាស្ហាស្ហ៊ូដ ។

២. ដាក់ប្រអប់ដៃលើភ្លៅ ម្រាមជៀតគ្នា ។

៣. សម្លឹងមើលទៅឯម៉ុស្ហ៍ ឬ ក្បាលជង្គង់ ។

៤. ក្រោយតាស្ហាស្ហ៊ូដទីមួយ មុសតាហ្ហាប់ឲ្យថា "វ៉ា



**ដាក់ថ្ងាសអ្នកលើដីដាស់អ្នកឲ្យនឹកឃើញ**
**ដើមកំណើតនៃការបង្កើតអ្នក**

**មេរៀនទី ៤**

# ស្វ៉ឡាត់ - អធិប្បាយលំអិតអំពី ទង្វើវ៉ាយីបក្នុងស្វ៉ឡាត់

**តាស្ហាស់ហ៊្វុដ(១)**

តាស្ហាស់ហ៊្វុដមានន័យថាប្តេជ្ញាចិត្ត ។ ជាឈ្មោះរបស់អ្វីដែលយើងសូត្រក្រោយសាចុ់ដ្ញាស់ទាំងពីរ ក្នុងរ៉ក់អាត់ទីពីរ និងរ៉ក់អាត់ចុងក្រោយរបស់ស្វ៉ឡាត់នីមួយៗ ។

តាស្ហាស់ហ៊្វុដជាវ៉ាយីប កុយរ៉ រុកនី (រូកុនវ៉ាយីប អនុលោម) ។ វាជាវ៉ាយីបមួយដងក្នុងស្វ៉ឡាត់ពីររ៉ក់អាត់ ក្រោយសាចុ់ដ្ញាស់ទាំងពីររបស់រ៉ក់អាត់ចុងក្រោយបំផុត ។ វាជាវ៉ាយីបពីរដងក្នុងស្វ៉ឡាត់បីរ៉ក់អាត់ ឬ បួនរ៉ក់អាត់ ក្រោយសាចុ់ដ្ញាស់ទីពីររបស់រ៉ក់អាត់ទីពីរ និងក្រោយសាចុ់ដ្ញាស់ចុងក្រោយរបស់រ៉ក់អាត់ចុងក្រោយ ។

តាស្ហាស់ហ៊្វុដមានដូចតទៅនេះគឺះ



أَشْهَدُ أَنْ لَا إِلَٰهَ إِلَّا ٱللَّهُ وَحْدَهُ لَا شَرِيكَ لَهُ، وَأَشْهَدُ أَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ. ٱللَّٰهُمَّ صَلِّ عَلَىٰ مُحَمَّدٍ وَآلِ مُحَمَّدٍ.

អាស្ហ៍ហាឌូ អាល់ឡា អ៊ីឡាហ្វា អ៊ីលឡុលឡ៏ហ៊្វូ វ៉ាស់ដ្ហាហ៊្វូ ឡា ស្ហារីកាឡាស់

វ៉ា អាស្ហ៍ហាឌូ អាន់ណា មូហ៊្វាំម៉ាដ្ញាន់ អាប់ឌូហ៊្វូ វ៉ា រ៉ស៊ូលុះហ្វ៍

អល់ឡ៏ហ៊្វុមម៉ា ស្វាល់លី អាឡា មូហ៊្វាំម៉ាដ្ញ៉ឌីវ វ៉ា អាលី មូហ៊្វាំម៉ាដ្ញ៉

**មានប្រាំប្រការវ៉ាយីបក្នុងតាស្ហាស់ហ៊្វុដ**

១. ត្រូវអង្គុយសូត្រ ។
២. ត្រូវឲ្យនឹងខ្លួនក្នុងពេលសូត្រ ។
៣. ត្រូវសូត្រជាភាសាអារ៉ាប់ ។
៤. មូវ៉ាឡាត់ - គឺត្រូវគោរពនិរន្តរភាព (កុំដាច់) ក្នុងពេលសូត្រ ។
៥. ត្រូវសូត្រដូចខាងលើនេះ ។

**តាស្ហាស់ហ៊្វុដជាសេចក្តីសង្ខេបរបស់ជំនឿយើង**

**មេរៀនទី ៥**

# ស្ឡាត់ - អធិប្បាយលំអិតអំពីទង្វើវ៉ាយីបក្នុងស្ឡាត់

**ការទិប និង មូវ៉ាឡាត់**

ការទិបនិងមូវ៉ាឡាត់ជាទង្វើវ៉ាយីបមួយប៉ែករបស់ស្ឡាត់ ។

ការទិបមានន័យថាលំដាប់ត្រឹមត្រូវរបស់ទង្វើនានា ។
មូវ៉ាឡាត់មានន័យថាភាពរលូនជានិរន្តរភាពក្នុងស្ឡាត់ ។

ប៉ែកនីមួយៗរបស់ស្ឡាត់ ចាំបាច់ត្រូវប្រតិបត្តទៅតាមលំដាប់ដែលច្បាប់បានចែងមក ។

ប្រសិនបើគេផ្លាស់ប្តូរលំដាប់របស់ប៉ែកវ៉ាយីប រុកន៍ (រូកុនវ៉ាយិប) របស់ស្ឡាត់ដោយចេតនា ឬ ដោយអចេតនា ស្ឡាត់ត្រូវមោឃៈ ។



តាកូប់បាល់ ស្វាហ្វាអ៊ុតាហ៊ូ វ៉ារហ្វាក់ ដ្វារ៉យ៉ាតាស់ (تقبل شفاعته و وارفع درجته សូមព្រះអង្គព្រមទទួលការជួយធ្វើអន្តរាគមន៍របស់ព្រះសាស្តា ឲ្យអស់ទូលព្រះបង្គំជាខ្ញុំនាថ្ងៃជំនុំជម្រះ ហើយសូមព្រះអង្គលើកតម្កើងឋានន្តរស័ក្តិឲ្យព្រះអង្គផង) ។

៥. ក្រោយតាស្វាស់ហ៊ូដទីពីរ មុសតាហ្វាប់ឲ្យថា "ស៊ុបហាណល់ឡោះហ្វ៍" (សូមថ្វាយសេចក្តីរុងរឿងចំពោះអល់ឡោះហ្វ៍) ។

**ស្ឡាវ៉ាតក្នុងតាស្វាស់ហ៊ូដឆ្លុះបញ្ចាំងឲ្យឃើញថាមូហាំម៉ាដ់ﷺ និងអាស់លុល-បៃត៍ព្រះអង្គមិនអាចញែកចេញបានពីស្ឡាត់ទេ**

**សាឡាម**

សាឡាមជាវ៉ាយីបចុងក្រោយរបស់ស្ឡាត់ ។ ជាវ៉ាយីបកុយរ៉ រុកនី (រូកុនវ៉ាយីបអនុលោម) ។ សាឡាមជាវ៉ាយីបក្រោយតាស្វាស់ហ៊ូដក្នុងរ៉ក់អ៊ុត់ចុងក្រោយ ។

សាឡាមវ៉ាយីបមានដូចតទៅ គឺៈ

**អាស់សាឡាមូ អាុឡៃណា វ៉ា អាុឡា អុ៊ីបាឌិលឡាហ៊្ហីស្វហ្វ៍លីហ៊ីន** ឬ
**អាស់សាឡាមូ អាុឡៃគុម វ៉ា រ៉ោះហ៊្មា៉ទុលឡ៍ហ្វី វ៉ា បារ៉កាទុះហ៍**

ទង្វើខាងក្រោមនេះជាវ៉ាយ៉ិបក្នុងសាឡាម គឺ៖

១. សូត្រឃ្លាណាមួយ ក្នុងចំណោមឃ្លាទាំងពីរខាងលើនេះ ។

២. ចាំបាច់ត្រូវសូត្រជាភាសាអារ៉ាប់ ។

៣. ចាំបាច់ត្រូវអង្គុយក្នុងពេលសូត្រ ។

៤. ចាំបាច់ត្រូវនៅស្ងៀមក្នុងពេលសូត្រ ។

សាឡាមជាទីបញ្ចប់របស់ស្វឡាត់ ។

អ្វីៗដែលហ្វារ៉ាំ (ត្រូវហាម) ក្រោយ "តាក់បីរ៉ទុល អ៊ិះហ៊្រ៉ម" ទៅជាហ្វាឡាល់ (អនុញ្ញាត) វិញ ក្រោយសាឡាមរួច ។

ទង្វើមុសតាហ្វាប់ក្នុងសាឡាមមាន៖



១. ការអង្គុយចាំបាច់ត្រូវឲ្យដូច ដែលបានរៀនរួចមក ហើយក្នុងមេរៀនសាច់ដ្ឋាស់ (យ៉ាលុស) ។

២. សូត្រសាឡាមទាំងពីរខាងលើនេះ ។

៣. សូត្រឃ្លាខាងក្រោមនេះ មុនសាឡាមទាំងពីរខាងលើនេះ គឺ៖

"**អាស់សាឡាមូ អាុឡៃកា អៃយូហ្វាន់ ណាប៊ីយូ វ៉ា រ៉ោះហ៊្មា៉ទុលឡ៍ហ្វី វ៉ា បារ៉កាទុះហ៍** (សូមឲ្យសិរីសួស្តី (របស់អល់ឡោះហ្វ៍) កើតមានដល់ព្រះអង្គ ឱបណ្ដាសាស្ដាអើយ ព្រមទាំងព្រះមេត្តាធម៌របស់អល់ឡោះហ្វ៍ និងពរជ័យរបស់ព្រះអង្គ) ។

៤. សូត្រតាក់បៀរបីដងក្រោយសាឡាម ។

**សាឡាមជាការរំលឹកនូវភាតរភាពក្នុងសាសនាអ៊ីស្លាម**

## មេរៀនទី ៦

# ស្វ៍ឡាត់ - មូណាហ្វីយ៉ាត់ក្នុងស្វ៍ឡាត់(១)

**អ្វីដែលធ្វើឲ្យស្វ៍ឡាត់មោឃៈ** (បាទិ្តល)

មានច្រើនទង្វើដែលអាចធ្វើឲ្យស្វ៍ឡាត់ របស់អ្នកមោឃៈ ។ ប្រសិនបើវាកើតមានឡើងត្រូវបំពេញស្វ៍ឡាត់សាថ្មី ។

មាន ១២ មូណាហ្វីយ៉ាត់ក្នុងស្វ៍ឡាត់ គឺ៖

១. អ្វីៗដែលធ្វើឲ្យវូឌុអ៊្មោឃៈ ឧទាហរណ៍ ដេកលក់ ឬ ដើរខ្យល់ ។
២. បែរចេញពីគិ្ឝបឡាស្វ ។
៣. គ្រប់ឥរិបថដែលបង្ហាញឲ្យឃើញថា ដូចជាមិនកំពុង បំពេញស្វ៍ឡាត់ទេ ឧទាហរណ៍ ទះដៃឬលោតជាដើម ។
៤. និយាយដោយចេតនា ។
៥. សើច ។
៦. យំដោយចេតនា ដោយសារអ្វីមួយពាក់ព័ន្ធនឹង



ប្រសិនបើគេផ្លាស់ប្តូរលំដាប់របស់ប៉ែករ៉ាឃ្វីប កុយ៉រ៉ រុកនី (រ្វកុនរ៉ាឃ្វិបអនុលោម) របស់ស្វ៍ឡាត់ដោយចេតនា ស្វ៍ឡាត់ត្រូវមោឃៈដែរ ។

ក៏ប៉ុន្តែ ប្រសិនបើគេផ្លាស់ប្តូរលំដាប់របស់ប៉ែករ៉ាឃ្វីប កុយ៉រ៉ រុកនី (រ្វកុនរ៉ាឃ្វិប អនុលោម) របស់ស្វ៍ឡាត់ដោយអចេតនា ស្វ៍ឡាត់មិនមោឃៈទេ ។

គ្រប់ទង្វើរបស់ស្វ៍ឡាត់ត្រូវប្រព្រឹត្តទៅយ៉ាងរលូន ឥតចន្លោះខុសធម្មតា ។ ប្រសិនបើអ្នកណាឈប់ក្នុងស្វ៍ឡាត់ ដែលអ្នកមើលអាចស្មានបានថាអ្នកនោះ មិនកំពុងតែបំពេញស្វ៍ឡាត់ទេ ស្វ៍ឡាត់របស់អ្នកនោះត្រូវមោឃៈ ។

### ការទីបនិងមូរ៉ាឡាត់ធ្វើឲ្យមុស្លីមទៅជាអ្នកមានសណ្តាប់ធ្នាប់និងមានវិន័យ

**តាក់ុគ្វីបាត់** (تعقيبات)

តាក់ុគ្វីបាត់មានន័យថាឌូអ៊ានិងតាស់ប៊ិះហ្វ ដែលគេសូត្រក្រោយស្វ៍ឡាត់ ។ គេឲ្យលើកតម្កើងអល់ឡោះហ្វﷻដោយសូត្រជាមួយផ្គាំផ្លែអង្កាំបីឃ្លាដូចតទៅ គឺ៖

**អល់ឡ៉ហ្វូ បាក់បារ ៣៤ ដង**
**អាល់ហាំឌូលិលឡាស់ ៣៣ ដង**
**ស៊ុបហាណល់ឡោះហ៍ ៣៣ ដង**

គេហៅតាស់ប៊ិះហ៍នេះថា "តាស់ប៊ីហ៊ុស ស្ហាស់រ៉អ៊ ‏(تَسْبِيح الزَّهْرَاء)" ព្រោះរ៉ស៊ូលុលឡោះហ៍ﷺបានបង្ហាត់តាស់ប៊ិះហ៍នេះ ឲ្យបុត្រីជាទីស្រឡាញ់របស់ព្រះអង្គﷺ ដែលមានព្រះនាមថា ហ្វាទីម៉ាស់ អាស់-ស្ហាស់រ៉អ៊ سلام الله عليها ។

មានឌូអាអ៊ច្រើនទៀតក្នុងតាក់គីបាត់ ដែលអាចទន្ទេញចាំរត់មាត់បាន យ៉ាងហោចណាស់ឌូអាអ៊ដែលគេសូត្រក្រោយស្ហ៍ឡាត់ប្រចាំថ្ងៃ ។

នេះគឺឌូអាអ៊ខ្លីមួយដកស្រង់ពីគួរអាន គឺ៖

| | |
|---|---|
| រ៉ប់បាណាក់ហ្វៀរ ឡាណា | -ព្រះម្ចាស់អើយ សូមព្រះអង្គអភ័យទោសឲ្យអស់ទូលព្រះបង្គំជាខ្ញុំ |
| វ៉ារហ្ាំណា | -សូមព្រះអង្គមានព្រះមេត្តាធម៌ដល់អស់ទូលព្រះបង្គំជាខ្ញុំ |



| | |
|---|---|
| វ៉ា អ៊ាហ្វីណា | -សូមព្រះអង្គប្រទានសេចក្តីសុខដល់អស់ទូលព្រះ បង្គំជាខ្ញុំ |
| វ៉ាក់ហ្វូអាន់ណា | -សូមព្រះអង្គលុបលាងបាបអស់ទូលព្រះបង្គំជាខ្ញុំ |
| ហ្វីដ្ឌុនយ៉ា វ៉ាល់ អាឃីរោះត៍ | -ក្នុងលោកនេះនិងលោកមុខ |
| អ៊ីនណាកា អ៊ាឡា គុល្លី | -ពិតណាស់ ព្រះអង្គមានមហិទ្ធិឫទ្ធិលើ |
| ស្ហៃអ៊ីនក៏ឌៀរ | -សព្វសារពើ |

**កុំប្រកាន់ខ្លួនពេកក្នុងការសូមអល់ឡោះហ៍**

មិនធ្វើឲ្យខូចស្វ៍ឡាត់ទេ ។

## ៤. និយាយដោយចេតនា

ប្រសិនបើនិយាយដោយចេតនា ក្នុងពេលកំពុងតែស្វ៍ឡាត់ ស្វ៍ឡាត់នោះត្រូវខូច ទោះបីនិយាយជាមួយខ្លួនឯងឬជាមួយអ្នកដទៃក៏ដោយ ឬនិយាយដោយចាំបាច់ ។ បើមានការចាំបាច់ អ្នកអាចនិយាយបានតែស្វ៍ឡាត់ត្រូវខូច អ្នកចាំបាច់ត្រូវបំពេញស្វ៍ឡាត់សាថ្មី ។

## ៥. សើចដោយចេតនា

សើចធ្វើឲ្យស្វ៍ឡាត់ខូច ។ ប្រសិនបើអ្នកចង់សើចខ្លាំង តែអ្នកទប់វាបានឡើងក្រហាមមុខ ស្វ៍ឡាត់របស់អ្នកមិនខូចទេ វៀរលែងតែអ្នកសើច ។

សើចមិនរាប់បញ្ចូលជាញញឹមទេ ។ ញញឹមមិនធ្វើឲ្យស្វ៍ឡាត់ខូចទេ ។

**ស្វ៍ឡាត់ត្រូវប្រព្រឹត្តទៅដោយមានសតិអារម្មណ៍និងដោយមានចិត្ត**



លោកសម្ភារនិយម ។

៧. ផឹក និង ស៊ី ។

៨. ឱបដៃដូចទង្វើរបស់មុស្លីមឯទៀត ក្នុងស្វ៍ឡាត់ពួកគេ ។

៩. ថា "អាមីន" ក្រោយសូរ៉ោះត៍ អាល់-ហ្វាំដ៍ ។

១០. អ្វីៗដែលមិនត្រឹមត្រូវ ក្នុងលក្ខខ័ណ្ឌចាំបាច់របស់ស្វ៍ឡាត់ ឧទាហរណ៍ ដឹងខ្លួនថាសំលៀកបំពាក់មិនបរិសុទ្ធ (ត៉ហ្មៀរ) ។

១១. មានការសង្ស័យក្នុងរ៉ក់អាត់ដំបូង ទាំងពីររបស់ស្វ៍ឡាត់ស៊ុស្វរ៍, អាស្វ៉រ៍, អ៊ីស្វាអ៍ និងក្នុងស្វ៍ឡាត់ស៊ុបហ្វ៍និងម៉ាក់រីប ។

១២. ថែមឬចោលប៉ែករ៉ាឃ៉ីប រុកន៍ (រុកុនរ៉ាឃ៉ិប) របស់ស្វ៍ឡាត់ ។

**មូណាហ្វីយ៉ាត់មានន័យថាអ្វីដែលធ្វើឲ្យស្វ៍ឡាត់មោឃៈ មាន ១២ ប្រការ**

# ស្វ៍ឡាត់ - មូណាហ្វីយ៉ាត់ ក្នុងស្វ៍ឡាត់(២)

## អ្វីដែលធ្វើឲ្យស៊្វឡាត់មោឃៈ

### ១. អ្វីៗដែលធ្វើឲ្យវូឌុអ៊ំមោឃៈ

បើសិនជាក្នុងពេលស៊្វឡាត់មានអ្វីមួយ ដែលធ្វើឲ្យវូឌុអ៊ំមោឃៈកើតឡើង (ដូចជាដើរខ្យល់ ដេកលក់ជាដើម...) ស៊្វឡាត់ទៅជាមោឃៈ ទោះបីទង្វើនោះកើតឡើងដោយចេតនា ឬដោយអចេតនាក៏ដោយ ។

### ២. បែរចេញពីគិបឡាស់

ក) យើងដឹងស្រាប់ហើយថា បែរចេញពីទិសគិបឡាស់ធ្វើឲ្យស៊្វឡាត់មោឃៈ បើបែរចេញលើសពី ៩៥ំ ទាំងសងខាង ។

ខ) ដូច្នេះ បើបែរចេញពីគិបឡាស់លើសពី ៩៥ំ ទោះដោយចេតនាក្តី ដោយអចេតនាក្តី ដោយសារមូលហេតុអ្វីផ្សេងក្តី ដូចជាខ្យល់ឬត្រូវច្រានជាដើម ។

គ) ក្នុងករណីបែរចេញលើសពី ៩៥ំ ទោះបីបែរតែក្បាល ឬ



បែរទាំងរាងកាយតែម្តងក៏ដោយ គឺដូចគ្នា ។

ឃ) ក្នុងករណីដែលការបែរចេញពីគិបឡាស់នោះ ធ្វើឲ្យស៊្វឡាត់មោឃៈ ត្រូវប្រតិបត្តិដូចតទៅ គឺ៖

-បើកើតឡើងដោយចេតនា ឬដោយសារអ្វីផ្សេង ស៊្វឡាត់ត្រូវមោឃៈ ។

-បើកើតឡើងដោយអចេតនា ហើយនឹកឃើញវិញក្រោយពេលស៊្វឡាត់ បានហួសទៅហើយ (ឧទាហរណ៍ ស៊្វឡាត់អាស្វរ៍ ហើយនឹកឃើញវិញក្រោយម៉ាក់រីប) មិនបាច់ក៏ដ្វទេ ។

-បើកើតឡើងដោយអចេតនា ហើយនឹកឃើញវិញមុនហួសពេលស៊្វឡាត់ ត្រូវធ្វើឡើងវិញ ។

### ៣. អ្វីដែលគេមិនអាចហៅថាស៊្វឡាត់បាន

ប្រសិនបើអ្នកណាមួយកំពុងតែបំពេញស៊្វឡាត់ ធ្វើអ្វីមួយដែលមុស្លីមត្រឹមត្រូវមើលមកឃើញថា ផ្ទុយពីការបំពេញស៊្វឡាត់ ស៊្វឡាត់នេះត្រូវមោឃៈ។ ឧទាហរណ៍ ទះដៃ លោតលេង ។ល ។ ទង្វើបែបនេះធ្វើឲ្យស៊្វឡាត់មោឃៈ ទោះបីដោយចេតនា ឬដោយអចេតនាក៏ដោយ ។

ក៏ប៉ុន្តែកម្រើកដៃ ឬបង្ហាញអ្វីមួយឲ្យអ្នកណាម្នាក់ដោយដៃ

គុនូត ។ល ។)

បើជាទ្បើងវិញពីជម្ងឺទប់បត់ជើងតូច ឬបត់ជើងធំ ឬដើរខ្យល់មិនបាននោះ មិនចាំបាច់ក្ហ៍ដ្ហ៍ស្វ៍ឡាត់ដែលបានធ្វើហើយទេកាលដែលនៅមានជម្ងឺនោះ ។ តែបើជាពីជម្ងឺវិញនៅក្នុងពេលដែលកំពុងបំពេញស្វ៍ឡាត៎ណាមួយ ត្រូវក្ហ៍ដ្ហ៍ស្វ៍ឡាត៎នោះឡើងវិញ ។

### ៣. ស្វ៍ឡាត៎ក្ហ៍ដ្ហ៍ - ធ្វើសងដូចម្ដេច

អ្នកណាមិនបានបំពេញស្វ៍ឡាត៎វ៉ាយ៉្ជីប ទាន់ពេលវេលាកំណត់ ត្រូវបំពេញស្វ៍ឡាត៎ក្ហ៍ដ្ហ៍ (គឺសង) វិញ ទោះបីអ្នកនោះបានដេកលក់ ពេញមួយពេលរបស់ស្វ៍ឡាត៎នោះក៏ដោយ ឬទោះបីអ្នកនោះបានបាត់បង់សតិអារម្មណ៍ក្នុងអំឡុងពេលនោះក៏ដោយ ។

មិនចាំបាច់ធ្វើតាមលេខរៀងរបស់ស្វ៍ឡាត៎ក្ហ៍ដ្ហ៍ទេ លើកលែងតែករណីស្វ៍ឡាត៎ ដែលច្បាប់ចែងមកដោយមានលេខរៀង ។



**មេរៀនទី ៧**

# ស្វ៍ឡាត៎ - ម៉ាសាអ៊ីល (مسائل បញ្ហា) នានា

### ១. របៀបបំពេញស្វ៍ឡាត៎ពេលធ្វើដំណើរតាមយន្តហោះ តាមរថយន្ត ឬ តាមរថភ្លើង

ស្វ៍ឡាត៎វ៉ាយ៉្ជីបជាអ៊ីបាដាត៎មហាសំខាន់មួយ ដែលមិនអាចបណ្ដែតបណ្ដោយបាន ទោះជានៅក្នុងស្ថានភាពណាក៏ដោយ ។ ធ្វើឲ្យស្វ៍ឡាត៎វ៉ាយ៉្ជីបទៅជាក្ហ៍ដ្ហ៍(قضى)ជាបាបធំមួយ ។ អ្នកជិតស្លាប់ក៏ដោយដែលនៅមានសតិអារម្មណ៍នៅឡើយត្រូវបំពេញស្វ៍ឡាត៎ដែលអាចធ្វើទៅបាន ។

អ្នកធ្វើដំណើរតាមយន្តហោះ តាមរថយន្ត ឬតាមរថភ្លើង ត្រូវបំពេញស្វ៍ឡាត៎ ប្រសិនបើអ្នកនោះគិតថាមុនបានដល់ទីដៅស្វ៍ឡាត៎របស់ខ្លួននឹងទៅជាក្ហ៍ដ្ហ៍ ។

ត្រូវប្រតិបត្តិតាមតំណាក់ការដូចតទៅគឺះ

១. បើអាចធ្វើបាន ត្រូវយកទឹកវូឌុអ៍ ។ បើមិនបានទេ ត្រូវធ្វើតាយ៉ាំមុមជួស ។

២. បន្ទាប់មក រកគីបឡាស់ដោយត្រីវិស័យ ឬដោយសួរអ្នកដឹង ។

៣. រួចហើយ នៀតហើយតាក់ប៊ីរ៉ទុលអ៊ីះហ្ររ៉មដោយបែរទៅរកគីបឡាស់ ។ ក្រោយពីនោះមកមិនបាច់បែរទៅរកគីបឡាស់ទេបើយន្តហោះ រថយន្តឬរថ ភ្លើងប្ដូរទិសដៅ ។

ល្អបំផុតបំពេញស្ម៍ឡាត់ឈរ បើអាចធ្វើបាន ពុំនោះទេស្ម៍ឡាត់អង្គុយ ។ បើស្ម៍ឡាត់បែបនេះក៏មិនអាចធ្វើបានដែរគេអាចរូគុអ៍ សាច់ដ្វាស់ បំពេញទង្វើងទៀតដោយសញ្ញាត្របកភ្នែក ។

ច្បាប់សំខាន់ គឺឲ្យខ្លួនប្រាណនិងសំលៀកបំពាក់ស្អាត ។ ប្រសិនបើវាទៅជាណាយ៉ីសក្នុងពេលធ្វើដំណើរ ហើយអាចផ្លាស់បាន ត្រូវផ្លាស់វាចេញ ។



បើមិនអាចធ្វើបានទេត្រូវតែបំពេញស្ម៍ឡាត់ តែត្រូវក៏ដ៍ក្រោយមក ។

**២. អាល់ហ្ររាដ្វាស់ (ឧបត្តិហេតុ)**

បើមានបញ្ហាពាក់ព័ន្ធនឹងការបត់ជើងតូច ការដើរខ្យល់ ឬផ្សេងទៀត តើច្បាប់ស្ហារីអ៊ាស់ចែងអ្វីខ្លះ ?

បើអ្នកណាមានជម្ងឺទប់បត់ជើងតូចមិនបាន ឬទប់បត់ជើងធំមិនបាន ឬទប់ដើរខ្យល់មិនបាន អ្នកនោះត្រូវប្រតិបត្តិដូចតទៅគឺៈ

១. បើអ្នកនោះជឿជាក់ថាអាចស្ម៍ឡាត់បាន ក្រោយវូឌុអ៍ក្នុងអំឡុងពេលរបស់ស្ម៍ឡាត់នោះ គប្បីស្ម៍ឡាត់ក្នុងអំឡុងពេលនោះ (ដែលនៅក្នុងចន្លោះពេលអារ៉ាល់និងពេលក៏ដ៍)

២. បើអ្នកនោះអាចទប់បត់ជើងតូច ឬបត់ជើងធំ ឬដើរខ្យល់ បានតែក្នុងអំឡុងពេលធ្វើទង្វើវ៉ាយ៉ីបប៉ុណ្ណោះ អ្នកនោះត្រូវចោលទង្វើស៊ូណាត់ (អ៊ីក៏ម៉ាត់ អាស្សាន

ពេលបំពេញស្ហ៍ឡាត់ ត្រូវនឹកដល់អល់ឡោះហ្វ៍عزوجلជានិច្ច ហើយបំពេញនមស្ការយ៉ាងរាបសា ។ ដល់ពេលបំពេញស្ហ៍ឡាត់ គេត្រូវស្មោរលាកំហុស ។

អ្នកណាចាត់ទុកថាស្ហ៍ឡាត់ជាអ្វីមួយធម្មតា មិនមានសារសំខាន់ អ្នកនោះនៅក្នុងចំពូកមនុស្សដែលមិនបានបំពេញស្ហ៍ឡាត់ទាល់តែសោះ ។

ព្រះសាស្តាﷺមានព្រះវចនៈថា អ្នកណាមិនចាត់ទុកថាស្ហ៍ឡាត់សំខាន់ទេ ហើយគិតថាឥតប្រយោជន៍ អ្នកនោះសមនឹងទទួលរងនូវទារុណកម្មនៅលោកមុខ (ពោលគឺ ក្នុងផ្នូរនិងក្នុងឋាននរក) ។

អល់ឡោះហ្វ៍عزوجلមានព្រះរាជបន្ទូល ក្នុងព្រះមហាគម្ពីរគួរអានថាអ្នកណាគេចវេះបំពេញស្ហ៍ឡាត់ អ្នកនោះអាចនឹងទៅជាកាហ្វៀរ ។ អ្នកណាមិនព្រមបំពេញស្ហ៍ឡាត់ទេ អ្នកនោះបដិសេធមិនទទួលស្គាល់ថាមានអល់ឡោះហ្វ៍عزوجل ហើយជាមុស្លីមតែឈ្មោះទេ ។

**អ្នកនោះសមនឹងរងទណ្ឌកម្មអល់ឡោះហ្វ៍យ៉ាងធ្ងន់**



ឧទាហរណ៍ ប្រសិនបើអ្នកមិនបានបំពេញស្ហ៍ឡាត់ស្ហ៊ុស្ហ៍រ និងស្ហ៍ឡាត់អាស្ហ៍រទេ ពេលបំពេញស្ហ៍ឡាត់ក៏ង៉្ហ៍ អ្នកត្រូវបំពេញស្ហ៍ឡាត់ស្ហ៊ុស្ហ៍រមុនស្ហ៍ឡាត់អាស្ហ៍រ ។ ប្រសើរបំផុតឲ្យរក្សាលេខរៀងនេះ ។ ដូចគ្នាដែរ ប្រសិនបើអ្នកមិនបានបំពេញស្ហ៍ឡាត់ស្ហ៊ុបហ៍ទេ ប្រសើរបំផុតឲ្យក៏ង៉្ហ៍ស្ហ៍ឡាត់ស្ហ៊ុបហ៍សិនមុនបំពេញស្ហ៍ឡាត់ស្ហ៊ុស្ហ៍រ ។

ប្រសិនបើអ្នកណាមិនបានបំពេញស្ហ៍ឡាត់ណាមួយ មិនបង្ខំខ្លួនឯងឲ្យក៏ង៉្ហ៍ទេ ថ្វីបើមានលទ្ធភាពគ្រប់គ្រាន់នោះ អ្នកនោះប្រព្រឹត្តខុសនិងប្រព្រឹត្តល្មើសយ៉ាងជាក់ស្តែង ចំពោះបទបញ្ជាអល់ឡោះហ្វ៍عزوجل ។
ក្រោយពីអ្នកនោះស្លាប់ទៅ កូនប្រុសបងគេរបស់អ្នកនោះចាំបាច់ត្រូវក៏ង៉្ហ៍ស្ហ៍ឡាត់របស់អ្នកនោះ ឬត្រូវជួលគេក៏ង៉្ហ៍ស្ហ៍ឡាត់នោះ ។ រីឯស្ហ៍ឡាត់ក៏ង៉្ហ៍របស់ម្តាយមិនចាំបាច់ឲ្យកូនប្រុសបងគេធ្វើទេ តែប្រសើរបំផុតគប្បីធ្វើ ។

ប្រសិនបើកូនប្រុសបងគេសង្ស័យថាឪពុកខ្លួនមាន ឬមិនមានស្ហ៍ឡាត់ដែលត្រូវក៏ង៉្ហ៍ទេនោះ គេមិនចាំបាច់ក៏ង៉្ហ៍ទេ ។

## មេរៀនទី ៨

# ស្វឡាត់ - ម៉ាសាអ៊ីល (បញ្ហា) នានា(២)

### ៤. ទណ្ឌកម្មនិងការខូចប្រយោជន៍ដោយសារពន្យារពេលស្វឡាត់វ៉ាយីប ដោយសារធ្វើឲ្យទៅជាក៏ដ្វ៏ (ផុតពេល) ឬមិនអើពើតែម្តង

ស្វឡាត់ជាវិធីគោរពបូជា ដែលត្រូវបញ្ញត្តក្នុងសាសនាអ៊ីស្លាម ។ គោរពបូជាគឺការចុះចូលចំពោះអល់ឡោះហ្ ﷻ ។

អល់ឡោះហ្ ﷻ ធំជាងគេបំផុត ! មិនមានអ្វីប្រៀបផ្ទឹមឡើយ ។ ពេលណាអល់ឡោះហ្ហៅអ្នក (នៅពេលស្វឡាត់) ពេលនោះត្រូវទុកភារកិច្ចលោកីយ៍មួយអន្លើសិន ។ **ចូរកុំខកខានក្នុងឱកាសមាសនេះឡើយ** ។ ចូរទៅស្វឡាត់ក្នុងវត្តមានអល់ឡោះហ្ ﷻ ។ ព្រះអង្គទ្រង់ធំសម្បើមណាស់ បញ្ហាយើង ការព្រួយបារម្ភឬឧបសគ្គយើងនឹងមានដំណោះស្រាយ បើយើងសូមព្រះអង្គដោយស្មោះ ។ មិនត្រឹមតែប៉ុណ្ណោះទេ សេចក្តីសប្បាយ ជោគជ័យនិងគោលដៅយើងច្បាស់ជាបានសម្រេច ។ យើងអាចចរចា ប្រស្រ័យជាមួយព្រះអង្គ



ដូចម្តេចទៅ ។ មានតែសេចក្តីស្រឡាញ់និងសេចក្តីប្រោសប្រណីរបស់ព្រះអង្គទេ ដែលអាចផ្តល់ឲ្យនូវសេចក្តីចម្រើនក្នុងលោកនេះនិងក្នុងលោកមុខ ។

បើអ្នកបំពេញស្វឡាត់ទាន់ពេលកំណត់ ហើយបន្តកិច្ចការផ្សេងៗនៅពេលក្រោយ អ្នកនឹងមានអារម្មណ៍ថាស្កប់ចិត្ត ។ **សាកល្បងមើលទៅ**!

អ្នកប្រើពេល ៣០ នាទីសម្រាប់បំពេញ ១៧ រ៉ក់អាត់ ដោយបូកបញ្ចូលតាក់គីបាត់ (تعقبات) ផង សរុបមាន ៤៥ នាទីក្នុងមួយថ្ងៃ ។ អ្នកគិតថាច្រើនឬ អល់ឡោះហ្ ﷻ ព្រះរាជទានឲ្យយើង ២៤ ម៉ោងក្នុងមួយថ្ងៃ ?

សម័យថ្ងៃមួយ ពេលដែលរ៉សូលុលឡោះហ្ ﷺ នៅក្នុងម៉ាស់យីដ្ណាបាវី បុរសម្នាក់បានចូលមក ហើយបានបំពេញស្វឡាត់យ៉ាងលឿន មិនបានបំពេញរុគុអ៊ុនិងសាជ់ដាស់ដោយផ្ចិតផ្ចង់ទេ ។ ព្រះសាស្តា ﷺ មានព្រះវចនៈថា៖ "បើបុរសនេះនៅតែបំពេញស្វឡាត់បែបនេះហើយស្លាប់ គាត់នឹងមិនស្លាប់ក្នុងសាសនាខ្ញុំទេ (ក្នុងឋានៈជាមុស្លីម) ។ ដូច្នេះ មិនត្រូវបំពេញស្វឡាត់លឿនទេ ។ ក្នុង

## មេរៀនទី ៩

# ស្វ៊ឡាត់ - កន្លែងស្វ៊ឡាត់

### ម៉ាសាអ៊ីលចាំបាច់

១. មិនអនុញ្ញាតឲ្យបំពេញស្វ៊ឡាត់លើកន្លែងកុស្វ៉ូបី (غصب របស់អ្នកដទៃ) ដោយឥតបានទទួលការអនុញ្ញាតទេ ។

២. កន្លែងសាច់ដាស់ត្រូវបរិសុទ្ធ (ត្ហ៊ីហ្វៀរ) ។ កន្លែងសម្រាប់ឈរនិងអង្គុយអាចមិនត្ហ៊ីហ្វៀរ កុំឲ្យតែណាយ៉ឹស (نجس) រាលដាលមកដល់រាងកាយនិងសំលៀកបំពាក់របស់អ្នកស្វ៊ឡាត់ ។

៣. មិនអនុញ្ញាតឲ្យបំពេញស្វ៊ឡាត់លើកន្លែងណា ដែលអ្នកស្វ៊ឡាត់មិនអាចបិតនៅនឹងមួយកន្លែង យ៉ាងល្អបាន ឬដែលមានគ្រោះថ្នាក់ ឧទាហរណ៍ លើផ្លូវដែលមានការទៅមកច្រើន ។

៤. កន្លែងអ្នកស្វ៊ឡាត់មិនត្រូវអស្ថិរវរ (មិនជាប់ ឬមិននឹង) ទេ ដូចជាពូកជាដើម ។



### ៥. សារសំខាន់របស់ការបំពេញស្វ៊ឡាត់ទៀងពេល

១. បំពេញស្វ៊ឡាត់យ៉ាងទៀងទាត់ក្នុងពេលកំណត់ ធ្វើឲ្យស្មារតីទៀងទាត់កាន់តែរីកចម្រើនឡើង ។

២. ស្វ៊ឡាត់ធ្វើឲ្យមនុស្សស្អាតស្អំ និងមានសណ្ដាប់ធ្នាប់រាងកាយរបស់គេមានការយកចិត្តទុកដាក់ និងមានរបៀបរបប ចិត្តគេបរិសុទ្ធ ។

៣. អ្នកបំពេញស្វ៊ឡាត់លាងដៃ លាងមាត់ ។ល ។ ប្រាំដងមួយថ្ងៃ ។ ប្រតិបត្តិបែបនេះកម្ចាត់អាការធុញទ្រាន់ ។

៤. អល់ឡោះហ្វ៍ទ្រង់ព្រះរាជទានចំណេះ ជំនឿនិងសុខភាពឲ្យអ្នកបំពេញស្វ៊ឡាត់ ។

៥. អល់ឡោះហ្វ៍ទ្រង់សព្វព្រះឫទ័យ អ្នកបំពេញស្វ៊ឡាត់ព្រមទាំងព្រះសាស្ដានិងព្រះសន្តអ៊ីម៉ាំ ។

៦. ស្វ៊ឡាត់ធ្វើឲ្យចិត្តថ្កើងថ្កាន ជម្រះមន្ទិល រម្ងាប់ចិត្តកម្ចាត់ឧបសគ្គខាងមុខ និងដោះស្រាយបញ្ហា ។

៧. រ៉ស៊ូលុលឡោះហ្វ៍មានព្រះវចនៈថា ស្វ៊ឡាត់ជាមេត្តាធម៌សម្រាប់អ្នកមានសទ្ធា ។

៨. ស្វ៊ឡាត់នឹងជួយយើងក្នុងលោកមុខ ។ ទេវតានឹងបួងសួងសូមខមាទោសឲ្យយើង និងជួយយើង ។

ស្វ៏ឡាត់ក្នុងលោកនេះជាចង្កៀង ឬជាពន្លឺយើងនៅក្នុងផ្នូរ ។

**គេនឹងព្រមទទួលទង្វើល្អទាំងអស់របស់បុគ្គល ប្រសិនបើអល់ឡោះហ៊្ ﷿ព្រមទទួលស្វ៏ឡាត់របស់បុគ្គលនោះ ។ ប្រសិនបើស្វ៏ឡាត់យើងត្រូវច្រានចោល គេនឹងមិនព្រមទទួលទង្វើល្អណាមួយរបស់យើងទេ ។**

យើងបានយល់សេចក្តីពណ៌នារបស់ស្វ៏ឡាត់ហើយ សង្ឃឹមថាម្នាក់ៗនឹងបំពេញ ស្វ៏ឡាត់ក្នុងពេលកំណត់យ៉ាងត្រឹមត្រូវ ។ តែចូរពិចារណាបន្តិចថា៖

អ្នកបំពេញស្វ៏ឡាត់ព្រោះតែ៖

ក) អ្នកខ្លាចអល់ឡោះហ្ ? បើដូច្នេះមែន អ្នកបំពេញស្វ៏ឡាត់របស់ទាសៈ ។

ខ) អ្នកស្វែងរករង្វាន់ ? បើដូច្នេះមែន អ្នកបំពេញស្វ៏ឡាត់របស់ឈ្មួញ ។

គ) ព្រះអង្គសមជាទីគោរពបូជា និងសមជាទីបំរើ ? បើដូច្នេះមែន នេះគឺស្វ៏ឡាត់ប្រសើរបំផុត ។

ចូរចងចាំថា អ៊ីម៉ាំអ៊ុាលី صلوات الله عليه والسلام មានវចនៈថា៖ "ប្រសិនបើអ្នក



បំពេញស្វ៏ឡាត់ដឹងថា ប៉ុន្មានព្រះមេត្តាធម៌របស់អល់ឡោះហ្វ៍ត្រូវប្រទានមកលើខ្លួនគេ ក្នុងពេលគេបំពេញស្វ៏ឡាត់នោះ អ្នកនោះច្បាស់ជាមិនព្រមងើបក្បាលឡើងពីការក្រាបណិប័តន៍ទេ !"

**ស្វ៏ឡាត់កម្ចាត់ភាពងងឹតពីក្នុងចិត្តដោយពន្លឺអភិវាទន៍**

## មេរៀនទី ១០

# ស្វ័ទ្បាត់ - សំលៀក
# បំពាក់សម្រាប់ស្វ័ទ្បាត់

ត្រូវគោរពវិន័យមួយចំនួនពាក់ព័ន្ធនឹងសំលៀកបំពាក់ ពេលបំពេញស្វ័ទ្បាត់ គឺ៖

១. សំលៀកបំពាក់ត្រូវតំ្ហហៀរ (បរិសុទ្ធ) ។ ស្វ័ទ្បាត់ជាមួយសំលៀកបំពាក់ណាយ៉ឹសត្រូវមោឃៈ ។

២. សំលៀកបំពាក់ត្រូវមូបាស្ហ៍ (مباح) មិនកុំស្ហ៍ប៊ី ។ ស្វ័ទ្បាត់ជាមួយសំលៀកបំពាក់កុំស្ហ៍ប៊ីត្រូវមោឃៈ ។ សំលៀកបំពាក់ដែលគេទិញដោយប្រាក់ ដែលមិនបានបង់ស្ហ៊ាកាត់ឬឃុមស៍ (កាលណាស្ហ៊ាកាត់ឬឃុមស៍នោះវ៉ាយ៉ឹប) ជាសំលៀកបំពាក់កុំស់ប៊ី ហើយស្វ័ទ្បាត់ជាមួយសំលៀកបែបនេះត្រូវមោឃៈ ។

៣. មិនត្រូវជាប៉ែកណាមួយរបស់សត្វដែលហ៊ារ៉ាំ បរិភោគសាច់ទេ ។ ដូច្នេះ រោមឆ្មា ឬរោមសត្វចំពូកនេះមិនត្រូវ



៥. កន្លែងត្រូវមានទំហំគ្រប់គ្រាន់សម្រាប់រូគុអ៊្ហ៍ និងសម្រាប់សាច៉្ហដាស្ហ៍បានយ៉ាងត្រឹមត្រូវ ។

៦. នារីគប្បីនៅខាងក្រោយបុរស ពេលបំពេញស្វ័ទ្បាត់ ។ យ៉ាងហោចណាស់ ឲ្យកន្លែងសាច៉្ហដ្ហាស្ហ៍នៅស្មើនឹងជ្ជរដែលបុរសដាក់ភ្លៅ ។ ឬឲ្យមានរាំងននឬជញ្ជាំងនៅត្រង់ចន្លោះពួកគេ ។

៧. កុំឲ្យកន្លែងដាក់ថ្ងាសនៅពេលសាច៉្ហដ្ហាស្ហ៍ ខ្ពស់ឬទាប ៤ ធ្លាប់ (បួនម្រាមដៃ) ជាងកន្លែងដាក់ជង្គង់និងម្រាមជើង ។

### ម៉ាស់យ៉ិដ្ហ

គេបញ្ជាក់ថាឲ្យបំពេញស្វ័ទ្បាត់ក្នុងម៉ាស់យ៉ិដ្ហ ។ ម៉ាស់យ៉ិដ្ហប្រសើររៀងតាមលំដាប់ គឺមាន៖

១. ម៉ាស់យ៉ិឌុល ហ៊ារ៉ម (នៅជុំវិញកាក់ហ្ហ៍បាស្ហ៍) ។ ស្វ័ទ្បាត់នៅទីនេះស្មើ ១០០០០០ ស្វ័ទ្បាត់នៅទីផ្សេងទៀត ។

២. ម៉ាស់យ៉ិឌុន ណាប៊ី (ម៉ាឌី្ហណាស្ហ៍) ។ ស្វ័ទ្បាត់នៅទីនេះស្មើ ១០០០០ ស្វ័ទ្បាត់នៅទីផ្សេងទៀត ។

៣. ម៉ាស់យ៉ិឌុល គូហ្វាស្ហ៍ និង បៃទុល មុកទ្ហ៍ដ្ហាស់ ។

ស្វ៍ឡាត្ញនៅទីនេះស្មើ ១០០០ ស្វ៍ឡាត្ញនៅទីផ្សេងទៀត ។

៤. ម៉ាស់យ៉ិដ្ឋ យ៉ាមីយ៉ា (ម៉ាស់យ៉ិដ្ឋស្រុក) ។ ស្វ៍ឡាត្ញនៅទីនេះស្មើ ១០០ ស្វ៍ឡាត្ញនៅទីផ្សេងទៀត ។

៥. ម៉ាស់យ៉ិដ្ឋសង្កាត់ (ម៉ាស់យ៉ិដ្ឋជិតខាង) ។ ស្វ៍ឡាត្ញនៅទីនេះស្មើ ១២ ស្វ៍ឡាត្ញនៅទីផ្សេងទៀត ។

សម្រាប់នារី ផ្ទះខ្លួនឯងប្រសើរជាងម៉ាស់យ៉ិដ្ឋ ។

ព្រះសាស្តាﷺយើងមានព្រះវចនៈថា ម៉ាស់យ៉ិដ្ឋនឹងត្អូញប្រាប់អល់ឡោះហ្វ៍ﷻ បើគេលែងអើពើវា ឬពុំមានមនុស្សមកស្វ៍ឡាត្ញទេ ។

ម៉ាស់យ៉ិដ្ឋល្បីជាងគេគឺម៉ាស់យ៉ិឌុល ហ្ការ៉ម នៅជុំវិញកាក្ញបាស្ញ ។ រង្វាន់មួយរ៉ក់អាត្ញស្មើ ១០០០០០ រ៉ក់អាត្ញស្វ៍ឡាត្ញនៅឯទីផ្សេង ។

**កន្លែងដែលម៉ាក់រុះហ្វ៍(مكروه)បំពេញស្វ៍ឡាត្ញ (យកល្អឲ្យចៀសវាង)**

១. កន្លែងងូតទឹកសាធារណៈ ។



២. ដីប្រៃ ។

៣. ទល់មុខមនុស្ស ។

៤. ទល់មុខទ្វារបើក ។

៥. លើផ្លូវ លើកលែងតែបំពេញស្វ៍ឡាត្ញនៅទីនោះមិនធ្វើឲ្យអ្នកផងរំខាន ។ បើដូច្នេះ ហ្ការ៉ាំមិនឲ្យបំពេញស្វ៍ឡាត្ញនៅទីនោះទេ ។

៦. ទល់មុខភ្លើងឬចង្កៀង ។

៧. ក្នុងផ្ទះបាយ ឬកន្លែងណាដែលមានទ្បូ ។

៨. ទល់មុខអណ្តូង ឬណ្តៅដែលគេបត់ជើងតូចដាក់ជាញឹកញយ ។

៩. កន្លែងដែលមានរូប (គំនូរ រូបថត ។ល ។) ទោះបីមិននៅទល់មុខអ្នកស្វ៍ឡាត្ញក៏ដោយ ។

១០. ទល់មុខផ្នូរ លើផ្នូរ ក្នុងចន្លោះផ្នូរ ឬនៅក្នុងស្មសាន (ទីបញ្ចុះសព) ។

បំពាក់ ឬលើខ្លួនរបស់អ្នកស្វ៍ឡាត់ ដែលមិនធំជាងចុងម្រាមដៃចង្អុល ។

គ) វត្ថុដែលគេមិនប្រើ សម្រាប់បិទបាំងខ្មាស់មនុស្សទេ ព្រោះតែតូចពេក ។ ឧទាហរណ៍ កន្សែងដៃ លេវ ចិញ្ចៀន ។ល ។ កុំឲ្យតែវាធ្វើអំពីសារធាតុណាយ៉ីស ។

ប្រសិនបើពុំមានសំលៀកបំពាក់ផ្សេងពីកុស្វ៍ប៊ី (លួចគេ) ឬធ្វើអំពីមាសឬសូត្រ ហើយបុគ្គលនោះចាំបាច់ត្រូវតែពាក់វា ដោយសារតែរងា ឬដោយសារតែមនុស្សឯទៀតនៅជុំវិញខ្លួន បុគ្គលនោះអាចបំពេញស្វ៍ឡាត់ជាមួយវាបាន តែបើអាចធ្វើទៅបាន បុគ្គលនោះត្រូវដោះវាចេញ ហើយបំពេញស្វ៍ឡាត់ផតសំលៀកបំពាក់ក្នុងបន្ទប់បិទទ្វារជិត ។

ប្រើវិន័យនេះដែរ បើបុគ្គលនោះមិនមានសំលៀកបំពាក់ផ្សេងពីសំលៀកបំពាក់កុស្វ៍ប៊ីទេ ឬសំលៀកបំពាក់ធ្វើអំពីស្បែកសត្វស្លាប់ឬសត្វហ្ការ៉ាំ (ហាមបរិភោគ) ។

ប្រសិនបើមិនមានសំលៀកបំពាក់ ផ្សេងពីសំលៀកបំពាក់មិនបរិសុទ្ធ (ណាយ៉ីស) ទេ ហើយមិនអាចជម្រះបន្សុទ្ធវាបានទេ បុគ្គលនោះត្រូវបំពេញស្វ៍ឡាត់ជាមួយសំលៀក



អនុញ្ញាតក្នុងស្វ៍ឡាត់ទេ ។

៤. មិនត្រូវជាប៉ែកណាមួយរបស់សត្វស្លាប់ទេ ។ ខ្សែក្រវ៉ាត់ឬរបស់ធ្វើអំពីស្បែកសត្វ មិនត្រូវអនុញ្ញាតទេ វៀរលែងតែវាស្របតាមច្បាប់ស្មាប៊ីហ្ការ៉ស្វ (ذبيحة ពេល គឺ មកពីសត្វហ្ការ៉ាឡាល់សំឡេះតាមច្បាប់អ៊ីស្លាម) ឬទិញមកពីមុស្លីម (ដោយដឹងថាគេស្គាល់បុគ្គលនេះ ឬយ៉ាងហោចណាស់គួរឲ្យជឿថាមុស្លីមនេះ បានទិញមកក្រោយពីបានពិនិត្យមើលច្បាស់ហើយ) ។

៥. សម្រាប់តែមនុស្សប្រុសទេ មិនត្រូវពាក់មាស (មាសសុទ្ធឬមាសលាយ) ។ មិនខុសទេបើមានអ្វីមួយធ្វើអំពីមាសនៅក្នុងហោប៉ៅ ។

៦. សម្រាប់តែមនុស្សស្រី មិនត្រូវស្លៀកពាក់អ្វីដែលធ្វើអំពីសូត្រសុទ្ធទេ ។

មាសនិងសូត្រសុទ្ធត្រូវហាមគ្រប់ពេល ចំពោះមនុស្សប្រុសជាពិសេសក្នុងពេលស្វ៍ឡាត់ ។ ពេលគឺសព្វវត្ថុដែលធ្វើអំពីមាស កងដៃ វ៉ែនតា ចិញ្ចៀន ខ្សែក... ។ តែសម្រាប់មនុស្សស្រី មាសនិងសូត្រសុទ្ធត្រូវអនុញ្ញាតគ្រប់ពេល លើកលែងតែសូត្រសុទ្ធក្នុងពេលស្វ៍ឡាត់ទេ ។

**វិន័យ (ហ្វ៊ូកុម) ផ្សេងៗទៀត**

១. ប្រសិនបើបុគ្គលណាមិនដឹងថារាងកាយ ឬសំលៀកបំពាក់របស់ខ្លួនឯងណាយ៉ីសទេ ហើយបានដឹងក្រោយពីបានស្វ័ឡាត្ជរួច ស្វ័ឡាត្ជរបស់អ្នកនោះមិនមោឃៈទេ ។

២. បើបុគ្គលនោះដឹងថារាងកាយ ឬសំលៀកបំពាក់របស់ខ្លួនឯងណាយ៉ីសហើយភ្លេច បានបំពេញស្វ័ឡាត្ជក្នុងសភាពនេះ រួចហើយនឹកឃើញវិញក្រោយស្វ័ឡាត្ជ អ្នកនោះគប្បីបំពេញស្វ័ឡាត្ជសាឡើងវិញ (បន្ទាប់ពីបានសម្អាតហើយ) បើនៅសល់ពេល ឬបំពេញស្វ័ឡាត្ជក៏ដ្វ័បើផុតពេលហើយ ។

៣. ប្រសិនបើសំលៀកបំពាក់ទៅជាណាយ៉ីស ក្នុងស្វ័ឡាត្ជ ហើយបើអាចយកណាយ៉ីសនោះចេញបាន ឬអាចធ្វើឲ្យបរិសុទ្ធបាន ដោយមិនរំខានស្វ័ឡាត្ជទេ បុគ្គលនោះត្រូវធ្វើដូច្នេះ ស្វ័ឡាត្ជនឹងមិនខូចទេ ។ ប្រសិនបើយកចេញមិនបាន ឬមិនអាចធ្វើឲ្យបរិទ្ធស្អាតវិញបានទេ ហើយបើនៅសល់ពេល បុគ្គលនោះត្រូវឈប់ស្វ័ឡាត្ជ ជម្រះឲ្យបរិសុទ្ធ ហើយបំពេញ



ស្វ័ឡាត្ជសាឡើងវិញ ។ ប្រសិនបើមិនមានពេលគ្រប់គ្រាន់ទេ ហើយមិនអាចដោះសំលៀកបំពាក់នោះបានទេ បុគ្គលនោះត្រូវស្វ័ឡាត្ជឲ្យចប់ជាមួយសំលៀកបំពាក់នោះ ស្វ័ឡាត្ជមិនខូចទេ ។ ប្រសិនបើបុគ្គលនេះអាចដោះសំលៀកបំពាក់ណាយ៉ីសនោះបាន តែមិនមានសំលៀកបំពាក់ផ្សេងទេ បុគ្គលនោះត្រូវបំពេញស្វ័ឡាត្ជលុះចប់ជាមួយសំលៀកបំពាក់នោះ ។ ប្រើវិន័យនេះដែរ ពេលណាប៉ែករាងកាយណាមួយទៅជាណាយ៉ីសក្នុងពេលស្វ័ឡាត្ជ ។

៤. គេអត់ឱនឲ្យក្នុងពេលស្វ័ឡាត្ជ ចំពោះណាយ៉ីសទាំងនេះគឺៈ

ក) ឈាមដែលចេញមកពីមុខរបួសឬដំពក បើពិបាកយកចេញឬផ្លាស់ក្រណាត់រុំយ៉ាងហោចណាស់ មួយថ្ងៃម្តង ។ តែបើឈាមនោះហូរទៅលើប៉ែកមួយទៀតរបស់រាងកាយ (ឆ្ងាយពីរបួស) ត្រូវជម្រះប៉ែកនោះឲ្យបរិសុទ្ធវិញ ។

ខ) ឈាម (ផ្សេងពីឈាមសព ឬឈាមកាហ្វៀរ ឬឈាមសត្វដែលសាច់មិនហ្វាឡាល់) នៅលើសំលៀក

ប្រវែងលើសវត្ថុនោះពីរដង ។

ឃ) **ម៉ាក់រីប** ក្រោយថ្ងៃលិចរហូតដល់ពណ៌ក្រហមបាត់ពីជើងមេឃ ។

ង) **អ៊ីស្ហាអ៍** ក្រោយពេលហ្វាឌ៏ឡាត់របស់ម៉ាក់រីប ។

២. **ពេលដាច់ខ្សែក និង ពេលរួម**

ក) **ស៊ូហ្វ៍រ៍** - អំឡុងពេលស្វ៍ឡាត់ ៤ រ៉ក់អ៊ាត់ក្រោយពាក់កណ្តាលថ្ងៃ ជាពេលដាច់ខ្សែកសម្រាប់តែស្វ៍ឡាត់ស៊ូហ្វ៍រ៍ទេ ។ បើអ្នកណាបំពេញស្វ៍ឡាត់អ៊ាស្វ៍រ៍ក្នុងពេលនេះ ស្វ៍ឡាត់នោះត្រូវខូច ។

ខ) **អ៊ាស្វ៍រ៍** - អំឡុងពេលស្វ៍ឡាត់ ៤ រ៉ក់អ៊ាត់មុនថ្ងៃលិច ជាពេលដាច់ខ្សែក សម្រាប់តែស្វ៍ឡាត់អ៊ាស្វ៍រ៍ទេ ។ បើអ្នកណាបំពេញស្វ៍ឡាត់ស៊ូហ្វ៍រ៍ក្នុងពេលនេះ ស្វ៍ឡាត់នោះត្រូវខូច ។

អំឡុងពេលក្នុងចន្លោះពេលស្វ៍ឡាត់ដាច់ខ្សែក ទាំងពីរនេះ



បំពាក់នោះ ស្វ៍ឡាត់នឹងត្រឹមត្រូវ មិនខូចទេ ។

**មេរៀនទី ១១**

# ស្វ័ឡាត់ - ពេលវេលាស្វ័ឡាត់

**ពេលវេលាសម្រាប់បំពេញស្វ័ឡាត់ប្រចាំថ្ងៃមានដូចតទៅគឺៈ**

ក. **ស៊ុបហ៍** (ស្វ័ឡាត់ហ្វាច់រ៍) - ចាប់ផ្ដើមនៅពេលស្ហុបហ៍ស្វ័ឌិក ចប់នៅពេលថ្ងៃរះ ។

ខ. **ស៊្ហុស្ហរ៍** (ស្វ័ឡាត់ពាក់កណ្ដាលថ្ងៃ) - ចាប់ផ្ដើមនៅពេលថ្ងៃជ្រេ ចប់នៅពេលដែលល្មមតែបំពេញស្វ័ឡាត់ ៤ រ៉ក់អ៊ាត់បានមុនថ្ងៃលិច ។

គ. **អ៊ាស្វ័រ** (ស្វ័ឡាត់ពេលថ្ងៃរសៀល) - ចាប់ផ្ដើមនៅក្រោយពេលដែលអាចបំពេញស្វ័ឡាត់ ៤ រ៉ក់អ៊ាត់បាន (គឺក្រោយស្វ័ឡាត់ស៊្ហុសរ៍) ចប់នៅពេលថ្ងៃលិច ។

ឃ. **ម៉ាក់រីប** (ស្វ័ឡាត់ពេលព្រលប់) - ចាប់ផ្ដើមនៅពេលក្រោយថ្ងៃលិច ចប់នៅពេលសល់ពេលល្មមតែបំពេញ



ស្វ័ឡាត់ ៤ រ៉ក់អ៊ាត់បាននៅពាក់កណ្ដាលអធ្រាត្រ ។

ង. **អ៊ីស្ហាអ៍** (ស្វ័ឡាត់ពេលយប់) - ចាប់ផ្ដើមនៅក្រោយពេលដែលល្មមតែបំពេញស្វ័ឡាត់ ៣ រ៉ក់អ៊ាត់បាន (គឺស្វ័ឡាត់ម៉ាក់រីប) ចប់នៅពេលពាក់កណ្ដាលអធ្រាត្រ ។

**អធិប្បាយលំអិត**

១. ពេល**ហ្វាឌីឡាត់** យកល្អគួរបំពេញស្វ័ឡាត់នៅពេលហ្វាឌីឡាត់ ព្រោះបានរង្វាន់ច្រើន ។ ពេលហ្វាឌីឡាត់សម្រាប់ស្វ័ឡាត់ប្រចាំថ្ងៃមានដូចតទៅ គឺៈ

ក) **ស៊ុបហ៍** ចាប់ផ្ដើមនៅពេលស្ហុបហ៍ស្វ័ឌិករហូតដល់មានពណ៌ក្រហមនៅជើងមេឃ ។

ខ) **ស៊្ហុស្ហរ៍** ចាប់ផ្ដើមពីពាក់កណ្ដាលថ្ងៃ (គឺពេលថ្ងៃជ្រេ) រហូតដល់ពេលដែល ស្រមោលរបស់វត្ថុអ្វីមួយមានប្រវែងស្មើវត្ថុនោះ ។

គ) **អ៊ាស្វ័រ** ក្រោយពេលហ្វាឌីឡាត់របស់ស្វ័ឡាត់ស៊្ហុស្ហរ៍ រហូតដល់ពេលដែល ស្រមោលរបស់វត្ថុអ្វីមួយមាន

ខ្លឹមសារ ចូរការពារភ្នែកអស់លោកពីអ្វីដែលត្រូវហាម ចូរការពារត្រចៀកអស់លោកពីអ្វីដែលមិនគប្បីត្រូវឮ ។"



ជាពេលរួមសម្រាប់ស្វ៍ឡាត៉ស្ហ៊ុស្វរ៍និងស្វ៍ឡាត៉អាស្វ៉រ៍ ។

គ) **ម៉ាក់រីប** - អំឡុងពេលស្វ៍ឡាត៉ ៣ រ៉ក់អាត៉ក្រោយពេលថ្ងៃលិចជាពេលដាច់ខ្សែក សម្រាប់តែស្វ៍ឡាត៉ម៉ាក់រីបទេ ។ បើអ្នកណាបំពេញស្វ៍ឡាត៉អ៊ីស្ហាអ៍ក្នុងពេលនេះ ស្វ៍ឡាត៉នោះត្រូវខូច ។

ឃ) **អ៊ីស្ហាអ៍** អំឡុងពេលស្វ៍ឡាត៉ ៤ រ៉ក់អាត៉មុនពាក់កណ្តាលអធ្រាត្រជាពេលដាច់ខ្សែក សម្រាប់តែស្វ៍ឡាត៉អ៊ីស្ហាអ៍ទេ ។ បើអ្នកណាបំពេញស្វ៍ឡាត៉ម៉ាក់រីបក្នុងពេលនេះ ស្វ៍ឡាត៉នោះត្រូវខូច ។

អំឡុងពេលក្នុងចន្លោះពេលស្វ៍ឡាត៉ដាច់ខ្សែក ទាំងពីរនេះជាពេលរួមសម្រាប់ស្វ៍ឡាត៉ម៉ាក់រីបនិងស្វ៍ឡាត៉អ៊ីស្ហាអ៍ ។

## មេរៀនទី ១២

# ស្ហៅម៍(១) (សីលត្រណមអាហារ)

**សីលត្រណមអាហារ** មានន័យថាចៀសវាងអ្វីដែលផ្តាច់សីលត្រណមចាប់ពីស្ហុបហ្ហ៍ ស្វ៉ឌិក្ខ (ព្រឹកមុនថ្ងៃរះពិតប្រាកដ) រហូតដល់ពេលម៉ាក់រិប (ពេលថ្ងៃលិច) ។

### ផលប្រយោជន៍របស់ខែរ៉ម៉ាដ្ហន

សម័យថ្ងៃមួយ ព្រះសាស្តាﷺបានសម្តែងធម៌ថា៖ "ប្រជារាស្ត្រអើយ ខែ (រ៉ម៉ាដ្ហន) របស់អល់ឡោះហ្វ៍عزوجلមកដល់ហើយជាមួយព្រះមេត្តាធម៌និងសិរីសួស្តីរបស់ព្រះអង្គعزوجل ។ ខែនេះជាខែដែលប្រសើរលើសខែទាំងអស់ សម្រាប់អល់ឡោះហ្វ៍ عزوجل ។ ថ្ងៃរបស់ខែនេះជាថ្ងៃប្រសើរបំផុត យប់របស់ខែនេះជាយប់ប្រសើរបំផុត ម៉ោងរបស់ខែនេះជាម៉ោងប្រសើរបំផុត ។ អល់ឡោះហ្វ៍عزوجلអញ្ជើញអស់លោកក្នុងខែនេះ (មកកាន់សីលត្រណមអាហារនិងធ្វើនមស្ការ) ។ ក្នុងខែនេះគេបានបើកឱកាសឲ្យអស់លោក ទទួលបាននូវកិត្តិយសពីអល់ឡោះហ្វ៍



عزوجل ព្រះដ៏មានព្រះខន្តី ។

ក្នុងអំឡុងខែនេះ បើអស់លោកកាន់សីលតមអាហារពិតប្រាកដ ដូចដែលគេបានដាក់បញ្ញមកលើអស់លោកមែននោះ រាល់ខ្យល់ដកដង្ហើមចេញចូលរបស់អស់លោកនឹងបានមកនូវរង្វាន់នៃតាស់ប៊ិះហ្វ៍ ឯដំណេករបស់អស់លោកនឹងបានមកនូវរង្វាន់នៃការគោរពបូជា ។ ទង្វើល្អរបស់អស់លោកនឹងត្រូវតបស្នងលើសពីថ្ងៃធម្មតា ឯការបួងសួង (ឌូអាអ៍) របស់អស់លោកនឹងអាចមានប្រសិទ្ធិភាពជាងសព្វដង ។ ដូច្នេះ អស់លោកត្រូវបង្ហាញខ្លួនចំពោះអល់ឡោះហ្វ៍عزوجلដោយចិត្តបរិសុទ្ធឥតបាបចិត្ត ។ ចូរអស់លោកបួងសួងអល់ឡោះហ្វ៍عزوجل ឲ្យព្រះអង្គعزوجلប្រទានពរជ័យដល់អស់លោកឲ្យអស់លោកបានកាន់សីលត្រណមតទៅទៀត ឲ្យអស់លោកបានសូត្រគួរអាន ។

ការពិត បុគ្គលណាមិនបានទទួលព្រះខន្តីមេត្តាពីអល់ឡោះហ្វ៍عزوجلទេ អ្នកនោះអាប់ឱន ហ្មងសៅ ។ ពេលអស់លោកកាន់សីលត្រណម ចូរនឹកឃើញអាការឃ្លាននិងអាការស្រេកនៅថ្ងៃគ្ញីយ៉ាម៉ាត់ (ថ្ងៃជំនុំជម្រះ) ។ ចូរដាក់ទានឲ្យជនក្រីក្រនិងអ្នកទ័លក្រ ។ ចូរគោរពអ្នកចាស់ទុំរបស់អស់លោក ។

ចូរអាណិតអាសូរយុវជនរបស់អស់លោក ហើយចូររាក់ទាក់ជាមួយញាតិ ។ ចូរការពារអណ្តាតអស់លោកពីសម្តីឥត

ថ្ងៃ មុនពេលស្ហ៊ុស្ហ៍រ ហើយពុំបានធ្វើអ្វីមួយដែលបណ្តាលឲ្យដាច់ត្រណមនោះទេ អ្នកនោះត្រូវនៀតកាន់សីលត្រណមអាហារ សីលព្រលាមរបស់អ្នកនោះនឹងមានសុពលភាព (គឺមិនខូចទេ)។ ដូចគ្នាដែរ បើគេចាប់ផ្តើមធ្វើដំណើរក្រោយពេលស្ហ៊ុស្ហ៍រ សីលត្រណមថ្ងៃនោះនៅតែមានសុពលភាព ។

## ផលប្រយោជន៍របស់ខែពិសិដ្ឋរ៉ម៉ាដ្ហន

"អល់ឡោះហ្វ៍ عز وجل អឺយ នេះគឺខែរ៉ម៉ាដ្ហន ។ ក្នុងខែនេះឯងដែលព្រះអង្គ عز وجل បានចាត់បញ្ជូនគួរអានមក ជាមគ្គុទេសក៍ដឹកនាំសម្រាប់មនុស្ស ជាសញ្ញាជាក់ច្បាស់មួយ សម្រាប់ញែកការពិតចេញពីវិរុទ្ធភាព ជាខែកាន់ត្រណមអាហារ ជាខែបំពេញការបួងសួង ជាខែសម្រាប់បែរមករកព្រះអង្គ عز وجل និងជាខែសូមស្មារលាកំហុស ។ ជាខែអត់ឱនទោសនិងអនុគ្រោះលោះលា ។ ជាខែដែលមាន "យប់អាល់-ក្វដ្ទ៍រ" ដែលជាខែប្រសើរលើស ១០០០ ខែ ។ អល់ឡោះហ្វ៍ عز وجل អឺយ សូមព្រះអង្គ عز وجل ព្រះរាជទានពជ័យ សិរីសួស្តីដល់មូហ៊ាំម៉ាដ្ទ៍ صلى الله عليه وآله وسلم ព្រមទាំងព្រះរាជកុលដ្ឋាន عليهم السلام របស់ព្រះអង្គ صلى الله عليه وآله وسلم ផង ។ សូមព្រះអង្គ عز وجل ឲ្យទូលព្រះបង្គំជាខ្ញុំបានទំនេរ ដើម្បីគោរពបូជាព្រះអង្គ عز وجل និងសូត្រព្រះគម្ពីរ ។"



## មេរៀនទី ១៣

# ស្ហៅម៍(២) (សីលត្រណមអាហារ)

### អ្វីដែលផ្តាច់សីលត្រណមអាហារ

១. បរិភោគ ។
២. ផឹក ។
៣. មុជក្បាលទាំងស្រុងក្នុងទឹក ឬ មុជទឹក ។
៤. ចង្អោរដោយចេតនា ។
៥. បណ្តោយឲ្យធូលីចូលដល់ក្នុងបំពង់ក ។

### សីលត្រណមអាហារមានច្រើនប្រភេទ

#### សីលត្រណមអាហារចាំបាច់(វ៉ាយ៉ិប)មួយចំនួន

១. ខែរ៉ម៉ាដ្ហន ។
២. ក្ហ៌ដ្ហ៍ខែរ៉ម៉ាដ្ហន ។
៣. ស្ហៅម៍កាហ្វ៍ហ្វារ៉ោះត្ហ៍ (كفارة) ឬព្រោះតែបានផ្អាកត្រណម ឬព្រោះតែមិនបានសម្រេច ។

៤. ស្នៅម៍ដែលជាវ៉ាយ៊ីបបន្ទាប់ពីបានសច្ចា (نذر) បានស្បថ (قسم) បានធ្វើកិច្ចព្រមព្រៀង (عهد) ។
៥. ស្នៅម៍កុំផ្វ័របស់ឪពុក វ៉ាយ៊ីបលើកូនប្រុសបងគេ (ក្រោយពីឪពុកស្លាប់) ។

**សីលត្រណមអាហារស៊ូណាត់**

១. រាល់ថ្ងៃក្នុងខែរ៉យ៉ាប់និងក្នុងខែស្វាក់បាន (شعبان) ឬតាមថ្ងៃណាដែលធ្វើទៅបាន ទោះបីមួយថ្ងៃក៏ដោយ ។
២. ថ្ងៃទី ១៣, ១៤ និង ១៥ រាល់ខែសុរិយគតិ ។
៣. ថ្ងៃទី ១៨ ខែ ស្ស៊ុល-ហ៊ីច្ចយ៉ាស្ (ذو الحجة - ថ្ងៃបុណ្យកុំខ្សៀរ) ។
៤. ថ្ងៃទី ២៤ ខែ ស្ស៊ុល-ហ៊ីច្ចយ៉ាស្ (مباهلة - ថ្ងៃបុណ្យមូបាហ្វាឡាស្) ។
៥. ថ្ងៃទី ២៤ ខែ រ៉យ៉ាប់ (មិអ៊្រ៉ច្ច)

**សីលត្រណមអាហារដែលត្រូវហាម**

១. កាន់ត្រណមពេលមានជម្ងឺ ។
២. ថ្ងៃទី ១ ខែ ស្នៅវ៉ាល់ (شوّال - ថ្ងៃបុណ្យអាល់-ហ្វិត្វ័រ) ។



៣. ថ្ងៃទី ១០ ខែ ស្ស៊ុល-ហ៊ីច្ចយ៉ាស្ (ថ្ងៃបុណ្យអាល់-ហ៊ាច្ច) ។

**សីលត្រណមអាហារដែលគប្បីចៀសវាង(ម៉ាក់រុះហ្វ៍)**

កាន់សីលត្រណមអាហារថ្ងៃទី ១០ ខែមូហ៊ារ៉ម (محرم) ជាម៉ាក់រុះហ្វ៍ (ថ្ងៃអាស្ស៊ូរ៉អ៊ុ عاشوراء) ។

**វ៉ាយ៊ីបពាក់ព័ន្ធនឹងសីលត្រណមអាហារ (លក្ខខ័ណ្ឌរបស់ស្នៅម៍)**

មានលក្ខខ័ណ្ឌមួយចំនួន ក្នុងការកាន់សីលត្រណមកាហារ គឺ៖

១. មានសុខភាពល្អ ។
២. ជាអ៊ីស្លាម ។
៣. មិនធ្វើដំណើរទេនៅពេលស៊្សុស្វ័រ ។
៤. មិនមានគ្រោះថ្នាក់ដោយសារជម្ងឺទេ នៅពេលកាន់សីលត្រណមអាហារ ។

ប្រសិនបើអ្នកដំណើរត្រឡប់ទៅទីលំនៅវិញ ឬ មកដល់កន្លែងណាមួយដែលគេចង់ស្នាក់នៅ ១០ ថ្ងៃឬលើសពី ១០

ទុក្ខដោយសារយោបល់នោះទេ ។

ក៏ប៉ុន្តែ កាលណាជំនឿដើមរបស់មុស្លីមជួបប្រទះគ្រោះថ្នាក់ ឬសាសនាអ៊ីស្លាមត្រូវរង្គើ (ឧទាហរណ៍ ពេលដែលស្រុកទេសចង់ផ្លាស់ប្តូរជំនឿរបស់ប្រជារាស្ត្រ ឬជួយជម្រុញឲ្យផឹកស្រានិងលេងល្បែងស៊ីសង) ពេលនោះម្នាក់ៗចាំបាច់ត្រូវបង្គាប់ឲ្យប្រព្រឹត្តិល្អ និងណែនាំកុំឲ្យប្រព្រឹត្តអំពើហាមប្រាម ទោះបីធ្វើបែបនេះនឹងត្រូវរងទុក្ខដោយសារទង្វើនេះក៏ដោយ ។



ប្រយោគខាងលើនេះបញ្ជាក់ថា ក្នុងចំណោមសិរីសួស្តីរបស់ខែនេះមាន៖ គួរអាន យប់អាល់-ក្វដ្ស៍ ការសូមស្មារលាទោសពៃរ៍ និងការយោគយល់និងការលើកលែង ទោសទៅវិញទៅមក ។

គ្រប់ទង្វើ ល្អក្តីអាក្រក់ក្តី មានទម្ងន់ជាងសព្វដងក្នុងខែនេះ ។ ដូច្នេះ ការដាក់ទានដែលជាទង្វើល្អរាល់ដងនោះ ក្នុងខែនេះ នឹងមានទម្ងន់ច្រើនជាង ។

ឯទង្វើអាក្រក់នោះ វាអាក្រក់គ្រប់ពេល តែវាអាក្រក់ជាងគេក្នុងខែរ៉ម៉ាដូន ។ សូត្រគួរអានជាទង្វើគួរឲ្យសរសើរទូទាំងឆ្នាំ តែក្នុងអំឡុងពេលកាន់សីលត្រណមអាហារ មានន័យខ្ពង់ខ្ពស់ជាងសព្វដង ។

ព្រះសាស្តាصلى الله عليه وآله وسلمមានព្រះវចនៈថា៖ "សព្វអ្វីៗសុទ្ធតែមាននិទាឃៈរដូវរបស់វា ឯនិទាឃៈរដូវរបស់គួរអានគឺខែរ៉ម៉ាដូន ។"

## មេរៀនទី ១៤

# អាំរ៍ ប៊ិល-ម៉ាក់រូហ្វ

وَلۡتَكُن مِّنكُمۡ أُمَّةٞ يَدۡعُونَ إِلَى ٱلۡخَيۡرِ وَيَأۡمُرُونَ بِٱلۡمَعۡرُوفِ
وَيَنۡهَوۡنَ عَنِ ٱلۡمُنكَرِۚ وَأُوْلَٰٓئِكَ هُمُ ٱلۡمُفۡلِحُونَ

*"ចូរឲ្យមាននៅក្នុងចំណោមពួកអ្នក នូវសហគមន៍មួយដែលហៅទៅរកសេចក្ដីល្អប្រពៃ បង្គាប់ឲ្យប្រព្រឹត្តល្អ[តាមព្រះគម្ពីរអល់ឡោះហ្ទ៍និងតាមព្រះសាស្ដាព្រះអង្គ] ហាមប្រព្រឹត្តអាក្រក់ (គឺហាមអ្វីដែលអល់ឡោះហ្ទ៍ហាម) ។ ជនទាំងនោះជាជនដែលនឹងបាននូវជ័យជំនះ [បានដល់សុខុមាលភាពនៃឋានសួគ៌] ។" (ស៊ី. ៣, អា. ១០៤)*

នេះគឺសសរទ្រូងអ៊ីស្លាមទី ៧ មានន័យថាបង្គាប់ឲ្យធ្វើល្អ ។ បើបុគ្គលណាមិន ប្រតិបត្តិតាមកាតព្វកិច្ចដែលអល់ឡោះហ្ទ៍ដាក់មកទេ យើងចាំបាច់ត្រូវណែនាំបុគ្គលនោះនៅលើមាគ៌ាត្រឹមត្រូវ ដោយសង្ឃឹមថាបុគ្គលនោះនឹងដឹកនាំខ្លួនតាមការចង្អុលណែនាំដែលយើងបានបង្ហាញគេ ។



នេះគឺសាខាមួយសំខាន់ណាស់ក្នុងសាសនាអ៊ីស្លាម ។ អ្វីៗដែលត្រូវអល់ឡោះហ្ទ៍ដាក់មកជាបញ្ញាហៅថាម៉ាក់រូហ្វ មានន័យថាកុសល (គឺសេចក្ដីល្អ) ។ ឧទាហរណ៍ ស្វ័ឡាត់ សីលត្រណមអាហារ ឃុមស៍ ស្ទាកាត់ និងពង្រឹងគ្រឹះសាសនាអ៊ីស្លាម ។ ត្រូវបូកបញ្ចូលក្នុងឧទាហរណ៍នេះផងដែរនូវអ្វីដែលជាអនុសាសន៍ ដូចជាផ្ដល់អាហារនិងទទួលភ្ញៀវ បង្ហាត់បង្រៀនសិក្ខាបទអ៊ីស្លាម សីលធម៌ (أخلاق) និងមានចរិយាគប្បី ។

បង្គាប់បុគ្គលឲ្យធ្វើល្អលើកដំបូងជាវ៉ាជិប លើកទីពីរជាស៊ូណាត់ ។

អាំរ៍ ប៊ិល-ម៉ាក់រូហ្វទៅជាវ៉ាជិបអាស្រ័យលើបួនលក្ខខ័ណ្ឌគឺ៖

១. អ្នកដឹងថាអ្វីល្អ អ្វីអាក្រក់ ។
២. អ្នកសង្ឃឹមថាគេនឹងប្រតិបត្តិតាមយោបល់ ដែលអ្នកឲ្យទៅគេ ។
៣. បុគ្គលដែលអ្នកឲ្យយោបល់នោះចចេសប្រព្រឹត្តខុស ។
៤. អ្នកដឹងថាពេលអ្នកឲ្យយោបល់ទៅគេ អ្នកនឹងមិនរង

**មេរៀនទី ១៦**

# តាវ៉ាល់ឡា(تولّى)

قُلۡ إِن كُنتُمۡ تُحِبُّونَ ٱللَّهَ فَٱتَّبِعُونِي يُحۡبِبۡكُمُ ٱللَّهُ وَيَغۡفِرۡ لَكُمۡ ذُنُوبَكُمۡۚ وَٱللَّهُ غَفُورٞ رَّحِيمٞ

*[សាស្តាអឺយ] ចូរអ្នកថ្លែង[ប្រាប់បណ្តាមនុស្ស]ថា៖ "បើអស់លោកស្រឡាញ់អល់ឡោះហ្វ៍ចូរតាមខ្ញុំ ។ អល់ឡោះហ្វ៍នឹងសព្វព្រះហឫទ័យអស់លោក ព្រះអង្គនឹងអត់ឱនឲ្យអស់លោកដែលបានសាងបាប ។ អល់ឡោះហ្វ៍ខមាទោស ព្រះអង្គមានព្រះមេត្តាករុណាប្រណី ។" (ស៊. ៣, អា. ៣១)*

តាវ៉ាល់ឡាជាសសរទ្រូងអ៊ីស្លាមទី ៩ មានន័យថាស្រឡាញ់ និងតាមសិក្ខាបទរបស់អាស្ហ៍លុល-បៃត៍عليهم السلام ។

គេបកប្រែតាវ៉ាល់ឡានៅក្នុងគម្ពីរគួរអានថា "ទិសដៅដែលមុស្លីមបែរទៅរកដើម្បីដឹកនាំខ្លួន" ។



**មេរៀនទី ១៥**

# ណាស្ហ៍យី អ៊ុនិល មុនការ

## (نهى عن المنكر)

كُنتُمۡ خَيۡرَ أُمَّةٍ أُخۡرِجَتۡ لِلنَّاسِ تَأۡمُرُونَ بِٱلۡمَعۡرُوفِ وَتَنۡهَوۡنَ عَنِ ٱلۡمُنكَرِ وَتُؤۡمِنُونَ بِٱللَّهِ

*"[ឱបណ្តាអ្នកមានសទ្ធាជ្រះថ្លា និងមានព្រហ្មចារិយធម៌អឺយ] ពួកអ្នកជាសហគមន៍ល្អបំផុតដែលបានលេចឡើងសម្រាប់បណ្តាមនុស្ស ។ ពួកអ្នកបង្គាប់ឲ្យធ្វើល្អ [តាមព្រះរាជក្រឹត្យដែលអល់ឡោះហ្វ៍ដាក់មក] ពួកអ្នកហាមប្រព្រឹត្តអំពើអាក្រក់ ពួកអ្នកមានសទ្ធាចំពោះអល់ឡោះហ្វ៍ ។" (ស៊. ៣, អា. ១១០)*

នេះគឺសសរទ្រូងអ៊ីស្លាមទី ៨ មានន័យថាហាមធ្វើអំពើណាដែលហ្វារ៉ាំ ។ យើងត្រូវប្រាប់អ្នកណាដែលធ្វើអំពើដែលអល់ឡោះហ្វ៍ហាមឲ្យចៀសវាងធ្វើអំពើនោះ ដោយសង្ឃឹម

ថាបុគ្គលនោះនឹងធ្វើតាមការចង្អុលណែនាំនេះ ។

"មុនការ" មានន័យថាអ្វីៗដែលត្រូវហាមក្នុងសាសនាអ៊ីស្លាម ដូចជា ផឹកសុរា លេង ល្បែងអ៊ីសង ស្តាប់តន្ត្រី បរិភោគសាច់ជ្រូក ។ល ។

ដូច "អាំរ៍ ប៊ិល-ម៉ាក់រូហ្វ" ដែរ អនុវត្តិ "ណាស៍យី អាំនីល មុនការ" លើកដំបូងជាវ៉ាយ៉ីប លើកទីពីរជាស៊ុណាត់ ។

មានបួនតំណាក់ការ ដើម្បីធ្វើឲ្យគេលែងហ៊ានប្រព្រឹត្តទង្វើទាំងនេះដែលសាសនាអ៊ីស្លាមហាម គឺ៖

១. ផ្ចត់អារម្មណ៍របស់បុគ្គលដែលអ្នកឲ្យយោបល់ ។
២. បង្ហាញទឹកមុខស្អប់ខ្ពើមចំពោះទង្វើរបស់បុគ្គល ដែលប្រព្រឹត្តអំពើដែលត្រូវហាម ។
៣. តាមរយៈសម្តី ឬយោបល់ ឬបម្រាម ឬតាមរយៈសម្តីខ្លាំង ។
៤. តាមរយៈកម្លាំងបាយដើម្បីបញ្ឈប់ទង្វើអាក្រក់ កុំឲ្យតែបុគ្គលនោះរងនូវសេចក្តីឈឺចាប់ ។ បុគ្គលនោះមិនត្រូវរងរបួសទេ ។

បុគ្គលដែលអនុវត្តិ "អាំរ៍ ប៊ិល-ម៉ាក់រូហ្វ" និង "ណាស៍យី



អាំនីល មុនការ" ជាបុគ្គលដែលអល់ឡោះហ៍វាយតម្លៃខ្ពស់ ។ ព្រះអង្គទុកដាក់ពួកគេក្នុងចំណោមបាវបម្រើព្រះអង្គដែលមានជោគជ័យ ។

"តាបារ៉" មានន័យថាចៀសឆ្ងាយពីជនអាក្រក់ ។ បើយើងមើលទៅឯពិភពលោក យើងនឹងឃើញថាទាំងបុគ្គល ទាំងរដ្ឋនានាប្រកាសបដិសេធអំពើអាក្រក់ ហើយចៀសចេញពីជនអាក្រក់ ។ ក្នុងករណីអំពើអាក្រក់ដែលមានទំហំវិសេសវិសាល គេសង្ឃឹមថារដ្ឋដែលមានអារ្យធម៌ទាំងអស់នឹងថ្កោលទោសអំពើអាក្រក់ ។

ដូចគ្នាដែរ សង្ឃឹមថាមុស្លីមគ្រប់រូបថ្កោលទោសអំពើអាក្រក់គ្រប់វេលា ដែលបានប្រព្រឹត្តនៅក្នុងប្រវត្តិសាស្រ្តអ៊ីស្លាម ។ បើពួកគេមិនធ្វើទេ ពួកគេត្រូវចាត់ទុកជាបក្សពួករបស់ពួកប្រព្រឹត្តអាក្រក់ ។

នៅក្នុងព្រះគម្ពីរគួរអាន អល់ឡោះហ្វ៍ហាមយ៉ាងច្បាស់ថាមិនឲ្យចងមិត្តភាពជាមួយជនណា ដែលជាសត្រូវរបស់អល់ឡោះហ្វ៍និងមុស្លីមទេ ។



ព្រះមហាគម្ពីរគួរអានចែងថា៖

وَلِكُلّٖ وِجۡهَةٌ هُوَ مُوَلِّيهَاۖ فَٱسۡتَبِقُواْ ٱلۡخَيۡرَٰتِۚ أَيۡنَ مَا تَكُونُواْ يَأۡتِ بِكُمُ ٱللَّهُ جَمِيعًاۚ إِنَّ ٱللَّهَ عَلَىٰ كُلِّ شَيۡءٖ قَدِيرٞ ١٤٨

*"ម្នាក់ៗមានគោលដៅមួយសម្រាប់បែរទៅរក ។ ដូច្នេះអ្នកទាំងឡាយចូរវៀសវៃសាងអំពើល្អ ។ ទោះជាពួកអ្នកនៅទិសទីតំបន់ណាក៏ដោយ អល់ឡោះហ្វ៍នឹងនាំពួកអ្នកទាំងអស់គ្នាមកវិញ ។ ពិតណាស់ អល់ឡោះហ្វ៍មានសព្វានុភាពលើសព្វសារពើ ។"* (ស៊ូ. ២, អា. ១៤៨)

សម្រាប់អស់មុស្លីម អាល់លុល-បៃត៍ﷺជាទិសដៅដែលត្រូវបែរទៅរកដើម្បីដឹកនាំខ្លួននិងដើម្បីប្រព្រឹត្តអំពើល្អ ។

ក៏ប៉ុន្តែសេចក្តីស្រឡាញ់នោះ គេមិនព្រមទទួលយកយ៉ាងពិតប្រាកដទេទោះបីនៅក្នុងលោកនេះក៏ដោយ ។ បង្ហាញនូវសេចក្តីស្រឡាញ់ចំពោះប្រទេសជាតិយើង ដែលជាមាតុភូមិយើងនោះ យើងមិនត្រឹមតែសច្ចាថានឹងស្មោះត្រង់ប៉ុណ្ណោះទេ យើងព្រមតាមច្បាប់និងបទបញ្ជារបស់ប្រទេសជាតិដែរ ។

ដូចគ្នាដែរ តាវ៉ាល់ឡាចង់ឲ្យយើងមិនត្រឹមតែស្រឡាញ់

អាស្ហ៍លុល-បៃត៍ប៉ុណ្ណោះទេ ថែមទាំងឲ្យយើងស្មោះត្រង់ចំពោះអាស្ហ៍លុល-បៃត៍ ហើយព្រមតាមគំរូអាស្ហ៍លុល-បៃត៍ផង ។



**មេរៀនទី ១៧**

# តាបារ៉ (تبرأ)

إِنَّ ٱلَّذِينَ يُؤْذُونَ ٱللَّهَ وَرَسُولَهُۥ لَعَنَهُمُ ٱللَّهُ فِى ٱلدُّنْيَا وَٱلْـَٔاخِرَةِ وَأَعَدَّ لَهُمْ عَذَابًا مُّهِينًا

*"ជនទាំងឡាយណាដែលប្រមាថអល់ឡោះហ្វ៍ និងព្រះសាស្តាព្រះអង្គ អល់ឡោះហ្វ៍ដាក់បណ្តាសាជនទាំងនោះក្នុងលោកនេះនិងលោកមុខ ។ ព្រះអង្គបានត្រៀមការដាក់ទោសដ៏ទាបថោកសម្រាប់ជនទាំងនោះ ។" (ស៊ូ. ៣៣, អា. ៥៧)*

នេះជាសសរទ្រូងអ៊ីស្លាមទី ១០ ។ មានន័យថាចេញមុខប្រឆាំងជនទាំងឡាយណា ដែលប្រព្រឹត្តអាក្រក់លើអស់បាវបម្រើសច្ចការីរបស់អល់ឡោះហ្វ៍ ។ ពេលណាយើងចៀសឆ្ងាយពីពួកនោះ ពេលនោះបានសេចក្តីថាយើងមិនយល់ស្របតាមអំពើអាក្រក់របស់ពួកនោះទេ ។

គ) នឹកឃើញវិញមុនសាច់ដ្វាស់ ក្នុងរ៉ក់អ្វាត់ខាងមុខ ។

ឃ) មិនមានវាក្យសម្ព័នមួយណាត្រឹមត្រូវទេ ។

៦. វាក្យសម្ព័នទាំងអស់ខាងក្រោមនេះ ជាទង្វើមុសតាហ្វាប់ទាំងអស់ក្នុងសាច់ដ្វាស់ លើកលែងតែ ៖

ក) ដាក់ថ្ងាសលើដី (កម្រាល) ។

ខ) សម្លឹងទៅឯច្រមុះ ។

គ) ដាក់ជង្គង់លើដី ។

ឃ) ថាតាក់បៀរមុនសាច់ដ្វាស់ ។

៧. តាស្ហាស្ហ៊ុហ្វ្វដ្ធមានន័យថា ៖

ក) អង្គុយ ។

ខ) ប្ដេជ្ញាចំពោះអល់ឡោះហ្វ ។



## លំហាត់ ១

ចូរជ្រើសរើសយកចម្លើយមួយ ហើយគូសជុំវិញចម្លើយនោះ ។

១. មាន ១០ ទង្វើវ៉ាយ៉ិបក្នុងស្វ៉ឡាត់ ។ ទង្វើដែលមិនមែនជាវ៉ាយ៉ិប រុកន៍ (រូកុនវ៉ាយ៉ិប) ហើយក៏មិនមែនវ៉ាយ៉ិប កុយ៉រុកនី (រូកុនវ៉ាយ៉ិបអនុលោម) នោះ គឺ៖

ក. តាក់ប៊ីរ៉ទុល អ៊ិះហ្វ្រ៉ម ។

ខ. នៀត ។

គ. មូវ៉ាឡាត់ ។

ឃ. គុនូត ។

២. ក្នុងចំណោមវាក្យសម្ព័ន្ធខាងក្រោមនេះ តើវាក្យសម្ព័នមួយណាដែលជាន័យត្រឹមត្រូវជាងគេរបស់ "វ៉ាយ៉ិប រុកន៍" ។

ក) ប៉ែកនានារបស់ស្វ៉ឡាត់ដែល ប្រសិនបើត្រូវបន្ថែមឬត្រូវកាត់បន្ថយ ដោយចេតនាធ្វើឲ្យស្វ៉ឡាត់មោឃៈ ។

ខ) ប៉ែកនានារបស់ស្វ៍ឡាត់ដែល ប្រសិនបើត្រូវបន្ថែមឬត្រូវកាត់បន្ថយដោយចេតនា មិនធ្វើឲ្យស្វ៍ឡាត់មោឃៈទេ ។

គ) ប៉ែកនានារបស់ស្វ៍ឡាត់ដែល ប្រសិនបើត្រូវបន្ថែមឬត្រូវកាត់បន្ថយដោយចេតនា ធ្វើឲ្យស្វ៍ឡាត់ត្រឹមត្រូវ ។

ឃ) មិនមានវាក្យសម្ព័ន្ធមួយណាត្រឹមត្រូវទេ ។

៣. ក្នុងពេលបំពេញស្វ៍ឡាត់ រ៉ាយ៉ិបឲ្យ ៖

ក) ថ្ងាសនិងម្រាមជើង ត្រូវដាក់លើកម្ពស់ខុសគ្នាពេលវាប៉ះដី ។

ខ) ថ្ងាសនិងម្រាមជើង ត្រូវដាក់លើកម្ពស់ស្មើគ្នាពេលវាប៉ះដី ។

គ) ថ្ងាសត្រូវខ្ពស់ជាងម្រាមជើង ។

ឃ) មិនមានវាក្យសម្ព័ន្ធមួយណាត្រឹមត្រូវទេ ។



៤. ប្រសិនបើបុគ្គលណាមិនអាចសាច៉្ដាស្វ៉ បាន ដោយសារជម្ងឺ ឬដោយសារមូលហេតុផ្សេង បុគ្គលនោះត្រូវសាច៉្ដាស្វ៉ តាមលំដាប់ដូចតទៅ គឺ៖

ក) បន្ទាបខ្លួនតាមសមត្ថភាពដែលអាចធ្វើបាន បន្ទាប់មក បុគ្គលនោះត្រូវសាច៉្ដាស្វ៉ ដោយកម្រើកប្រអប់ដៃ ឬប៉ែកផ្សេងទៀតរបស់រូបកាយ ។

ខ) សាច៉្ដាស្វ៉ដោយឱនក្បាល ។

គ) សាច៉្ដាស្វ៉ដោយបិទភ្នែក ។

ឃ) វាក្យសម្ព័ន្ធទាំងអស់សុទ្ធតែត្រឹមត្រូវ ។

៥. ប្រសិនបើបុគ្គលណាភ្លេចសាច៉្ដាស្វ៉ ស្វ៍ឡាត់របស់បុគ្គលនោះត្រឹមត្រូវបើបុគ្គលនោះ ៖

ក) នឹកឃើញវិញមុនរូគុអ៍ខាងមុខ ។

ខ) នឹកឃើញវិញក្រោយពីបានបំពេញស្វ៍ឡាត់ចប់ ។

កុយ៉រ៍, អង្គុយ, មូវ៉ាឡាត់

តាស្វាស្ទ់ហ្វ៊ូដ្ទមានន័យថា______ ។ គេសូត្រតាស្វាស្ទ់ហ្វ៊ូដ្ទក្នុងរ៉ក់អ៊ាត្ទ៉ុទី______ និងក្នុងរ៉ក់អ៊ាត្ទ៉ុ__________ ។ តាស្វាស្ទ់ហ្វ៊ូដ្ទជាវ៉ាយ៉ើប______រុកន៍ក្នុងស្វ៉ឡាត្ទ៉ុ ។ ត្រូវសូត្រតាស្វាស្ទ់ហ្វ៊ូដ្ទក្នុងពេលដែលអ្នក______ ។ អ្នកត្រូវតែ_______មិនកម្រើកខ្លួនទេក្នុងពេលនោះ ។ ត្រូវតែសូត្រជាភាសា_____ ហើយត្រូវមាននិរន្តរភាព នេះគឺ________ ។ តាស្វាស្ទ់ហ្វ៊ូដ្ទជាសេចក្តីសង្ខេបរបស់_____យើង ។

២. ចូរសរសេររបៀបសូត្រតាស្វាស្ទ់ហ្វ៊ូដ្ទ វ៉ាយ៉ើប និង ស្វូណាត្ទ៉ុដែលបានសិក្សារួចមកហើយ ។ ចូរផាត់ព័ណ៌ បៃតងត្រង់កន្លែងសូត្រស្វូណាត្ទ៉ុ ព័ណ៌ក្រហមត្រង់កន្លែងសូត្រវ៉ាយ៉ើប ។ ចូរសរសេរសម្រាយរបស់តាស្វាស្ទ់ហ្វ៊ូដ្ទ ។

៣. ចូរសរសេររបៀបសូត្រសាឡាម ។ ចូរបញ្ជាក់សាឡាមស្វូណាត្ទ៉ុ និង សាឡាម វ៉ាយ៉ើប ។

៤. សាឡាមជាទង្វើចុងក្រោយក្នុងស្វ៉ឡាត្ទ៉ុ ។ ពេលណាអ្នកសូត្រសាឡាម អ្នក________ស្វ៉ឡាត្ទ៉ុរបស់អ្នក ។ អ្វីៗដែលត្រូវហាមសម្រាប់អ្នក នឹងទៅជា_________សម្រាប់អ្នក



គ) សូត្រស្វូរ៉ោះត្ទ៍ អាល់-ហ្វាំដ្ទ៍ និង ស្វូរ៉ោះត្ទ៍ អាល់-អ៊ិះខ្លាស់ ។

ឃ) មិនមានវាក្យសម្ព័នមួយណាត្រឹមត្រូវទេ ។

៨ វ៉ាយ៉ើប កុយ៉រ៍ រុកនី មានន័យថា ៖

ក) ប៉ែកនានារបស់ស្វ៉ឡាត្ទ៉ុដែល ប្រសិនបើត្រូវបន្ថែម ឬត្រូវកាត់បន្ថយដោយចេតនា ធ្វើឲ្យស្វ៉ឡាត្ទ៉ុមោឃៈ ។

ខ) ប៉ែកនានារបស់ស្វ៉ឡាត្ទ៉ុដែល ប្រសិនបើត្រូវបន្ថែម ឬត្រូវកាត់បន្ថយដោយចេតនា មិនធ្វើឲ្យស្វ៉ឡាត្ទ៉ុមោឃៈទេ ។

គ) ប៉ែកនានារបស់ស្វ៉ឡាត្ទ៉ុដែល ប្រសិនបើត្រូវបន្ថែម ឬត្រូវកាត់បន្ថយដោយអចេតនា ធ្វើឲ្យស្វ៉ឡាត្ទ៉ុមោឃៈ ។

ឃ) មិនមានវាក្យសម្ព័នមួយណាត្រឹមត្រូវទេ ។

៩ មានទង្វើវ៉ាយ៉ើបប្រាំក្នុងសាច់ដ្វាស់ ។ វាក្យសម្ព័នដែលមិនមែនជាវ៉ាយ៉ើប គឺ៖

ក) រូបកាយប្រាំពីរប៉ែកត្រូវប៉ះដី (កម្រាល) ។

ខ) ត្រូវនៅនឹងមួយកន្លែង ពេលសូត្រស៊ីករ៍

សាច់ដ្វាស់ ។

គ) ត្រូវសូត្រជាភាសាអារ៉ាប់ ។

ឃ) មើលទៅឯច្រមុះ ។

១០ ប្រសើរជាងគេគឺសាច់ដ្វាស់លើដុំដីដែលមកពី ហ្ការ៉ម អ៊ីម៉ាំ ហ៊្វសែន៍صلوات الله عليه والسلام នៅឯការបាឡា ។ គេហៅដុំដីនោះថា៖

ក) ទូរបាទុល ហ៊្វសៃនីយ៉ាស់ ។

ខ) ខាក់ ស្វីហ្វាអ៊ុ ។

គ) តាស់ប៊ិះហ្ក ហ្វាទីម៉ាស់ ។

ឃ) វាក្យសម្ព័នពីរ ក) និង ខ) ។

## លំហាត់ ២

វាក្យសម្ព័នខាងក្រោមនេះត្រូវឬខុស ។ ត្រូវសរសេរថា "ត" ខុសសរសេរថា "ខ" នៅលើគំនូស ។

១. ហ្ការរាំសាច់ដ្វាស់ដាក់អ្វីផ្សេងពីអល់ឡោះហ្វ ។______

២. ស៊្វណាត់ឲ្យសូត្រគ្នូរអានពេលសាច់ដ្វាស់______

៣. មិនអាចសាច់ដ្វាស់លើដីឬខ្សាច់បានទេ ព្រោះថ្វាសមិននឹង ។______



៤. គេអនុញ្ញាតឲ្យយើងសាច់ដ្វាស់ លើសំបកផ្លែឈើបាន ។______

៥. ពេលចុះសាច់ដ្វាស់ បុរសគប្បីដាក់ជង្គង់លើដីជាមុន ។______

៦. ពេលចុះសាច់ដ្វាស់ នារីគប្បីដាក់ប្រអប់ដៃលើដីមុនជង្គង់ ។_____

៧. មិនអនុញ្ញាតឲ្យអ្នកសាច់ដ្វាស់ លើអាវយឺតអ្នកទេ ។_____

៨. មិនអនុញ្ញាតឲ្យអ្នកសាច់ដ្វាស់ លើសំលៀកបំពាក់អ្នកទេ ទោះបីអ្នកមិនមានអ្វីដែលគេអនុញ្ញាតឲ្យសាច់ដ្វាស់លើ ក៏ដោយ ។_____

៩. ប៊ីប៊ីហ្វាទីម៉ាស់سلام الله عليهاសូត្រតាស់ប៊ិះហ្កមុនគេ ។_____

១០. ដាក់ក្បាលយើងលើដី ជាការរំលឹកដល់ពលីកម្មជីវិតរបស់អ៊ីម៉ាំហ៊្វសែន៍عليه السلام ។___

## លំហាត់ ៣

១. ចូរបំពេញចន្លោះទទេដោយពាក្យខាងក្រោមនេះ គឺ៖ នៅស្ងៀម, វ៉ាយ៉ើប, ២, ចុងក្រោយ, អារ៉ាប់, ជំនឿ, ធ្វើសាក្សី,

ស្វឡាត់ ។ តើអ្នកនឹងធ្វើយ៉ាងណា ?

## លំហាត់ ៧

តើអ្នកធ្វើយ៉ាងណាក្នុងស្ថានការណ៍ខាងក្រោមនេះ គឺ៖

១. អ្នកធ្វើដំណើរតាមយន្តហោះអ្នកចង់បំពេញស្វឡាត់ ។

២. អ្នកធ្វើដំណើរហើយអ្នកចង់បំពេញស្វឡាត់ ។ ខ្លួនអ្នក និងសំលៀកបំពាក់អ្នកណាយ៉ឺស (ព្រោះបានចូលបង្គន់ ហើយមិនមានទឹក) ។ មិនមានមធ្យោបាយជម្រះទេ ឯពេលវេលាក៏កំពុងតែចូលដល់ពេលក្ហ៊្ហ ។

៣. មិត្តអ្នកតែងតែបំពេញស្វឡាត់ស្វុបហ្វក្ហ៊្ហ ព្រោះគេគិតថាស្វឡាត់ស្វុបហ្វមានតែពីររ៉ក់អាត់ វាមិនសំខាន់ទេ ។

៤. ម៉ោង ១៦:៣០ ជាម៉ោងក្ហ៊្ហ ។ មិត្តអ្នកបបួលអ្នកមើលទូរទស្សន៍ ហើយនឹងបំពេញស្វឡាត់នៅម៉ោង ១៦:១៥ ព្រោះពុំមានតារាងមើលម៉ោងឲ្យជាក់ច្បាស់ទេ ហើយនៅមានពេលគ្រប់គ្រាន់មុនដល់ពេលក្ហ៊្ហ ។



ពេលនោះ ។ សូត្រតាក់បៀរ____ដងជាមុសតាហ្វាប់ក្រោយពីបានសូត្រសាឡាម ។ សាឡាមជាការរំលឹកនូវ_______ក្នុងសាសនាអ៊ីស្លាម ។

៥. ចូរសរសេរសម្រាយរបស់សាឡាម ។

## លំហាត់ ៤

១. ទង្វើភាគច្រើន ឬទាំងអស់តែម្តងក៏អាចថាបាន ត្រូវប្រព្រឹត្តទៅតាមលំដាប់ត្រឹមត្រូវ គេហៅរបៀបធ្វើនេះថា_______ ។ និរន្តរភាពនិងភាពខ្ជាប់ខ្ជួនក្នុងទង្វើនិងក្នុងការសូត្រជាកត្តាសំខាន់ដែរ ដែលគេហៅថា_______ ។

២. តារទីបនិងមូវ៉ាឡាត់ធ្វើឲ្យមុស្លីមទៅជាអ្នកមាន_______
_________ ។

៣. តាក់គ្វីបាត់មានន័យថា______និង_______ ។ ដែលគេសូត្រក្រោយស្វឡាត់ ។ តាស់ប៊ិះហ្វដែលគេស្គាល់ជាងគេគឺតាស់ប៊ិះហ្វរបស់ប៊ីប៊ីហ្វាទីម៉ាស់ سلام الله عليها ដែលរួមមានបីឃ្លាខ្លីៗ គឺ៖

______________________________ ស្វូត្រ___ដង ។

______________________________ ស្វូត្រ___ដង ។

______________________________ ស្វូត្រ___ដង ។

## លំហាត់ ៥

ចូរអានអត្ថបទខាងក្រោមនេះ ហើយចូរអធិប្បាយថាហេតុអ្វីស្ទ៍ឡាត់របស់ត៏លិបត្រូវមោឃ: ដោយគូសពីខាងក្រោមប៉ែកនោះដែលធ្វើឲ្យស្ទ៍ឡាត់មោឃ: ។

ត៏លិបមកពីសាលារៀនវិញ ម៉ោងប្រមាណ ១៥:៩៥ ។ ដោយដឹងថាស្ទ៍ឡាត់នឹងទៅជាក៏ដ៏ ម៉ោង ១៦:០០ វាក៏បានចាប់ផ្ដើមបំពេញស្ទ៍ឡាត់យ៉ាងលឿន ហើយដូចសព្វដងដែរ វាមិនអាចតាំងស្មារតីឲ្យបានមាំមួនទេក្នុងពេលស្ទ៍ឡាត់ ។ វាគិតទៅដល់អ្វីៗដែលវាបានធ្វើក្នុងថ្ងៃនោះ ដូចជាការប្រកួតបាល់ទាត់ដែលវាឈ្នះនៅឯសាលារៀនពេលសម្រាក ពេលវាកុហកគ្រូវាថា (ដោយអះអាងថាវាបានធ្វើបាត់សន្លឹកក្រដាស់លំហាត់) ហើយក៏បានភ្លេចទៅ ។ វាបានសើចក្នុងរ៉ក់អ៊ាត់ទីមួយព្រមនឹងស្វូត្រ ។ ពេលងើបឡើងពីរូគុអ៊ុំមកគ្នីយ៉ាម វានឹកឃើញពេលដែលវាបានទាត់ចូលកូល វាក៏



បានស្រែកឡើងថា "កូល !" ហើយលោតឡើងមុនបំពេញស្ទ៍ឡាត់បន្តដោយចុះទៅបំពេញសាច់ដ្វាស់ ។ ម្ដាយវាបានឃើញស្ទ៍ឡាត់ចម្លែកនេះដោយចៃដន់ គាត់បានបញ្ឈប់វាភ្លាមបានស្ដីបន្ទោសវា បានដាក់ទណ្ឌកម្មវាដោយហាមវាលេងកីឡាគ្រប់ប្រភេទអស់ពីរសប្ដាហ៍ ។ គាត់បានឲ្យវាបំពេញស្ទ៍ឡាត់សាថ្មី ។ វាក៏បានបំពេញស្ទ៍ឡាត់ម្ដងទៀតស្វូត្រអាល់-ហ្វាំដ្វ៍ព្រមទាំងឃំជាប់ ។

## លំហាត់ ៦

មិត្តមុស្លីមស៊ុន្នីរបស់អ្នក បានបបួលអ្នកទៅលេងម៉ាស់ឃ្វីដជិតខាងដើម្បីនឹងស្វែងយល់គ្នាទៅវិញទៅមក ។ នៅពេលដើរមើលគេបានសូមឲ្យអ្នកចូលរួមក្នុងស្ទ៍ឡាត់ ឃ្វុមអ៊ាស្ទ់នៅពេលស្ទ៍ឡាត់អ៊ាស្ទ់រ៍ ។ អ្នកបានបំពេញស្ទ៍ឡាត់អ៊ាស្ទ់រ៍ជាមួយស្ទ៍ឡាត់ស៊ូហ្វ៊ូររួចហើយ ។ ចូររលឹកឡើងវិញថាពួកមុស្លីមស៊ុន្នីបំពេញស្ទ៍ឡាត់ស៊ុហ្វ៊ូរនិងអ៊ាស្ទ់រ៍បែកគ្នា ។

អ្នកមិនដឹងនិយាយថាអ្វី មិនដឹងធ្វើយ៉ាងណា អ្នកបារម្ភព្រោះអ្នកបានបំពេញស្ទ៍ឡាត់ស៊ូហ្វ៊ូររួចហើយ ។ ពួកមុស្លីមស៊ុន្នីថា "អាមីន" ក្រោយអាល់-ហ្វាំដ្វ៍ ឱបដៃពេលបំពេញ

(វ៉ាឃ្វីប/ស៊ូណាត់/ម៉ាក់រុះហ្វ/ហ្ារ៉ាំ) ។

២. វាក្យសម្ព័ន្ធខាងក្រោមនេះត្រូវឬខុស ? ចូរសរសេរ "ត" ឬ "ខ" នៅក្បែរឃ្លា ។

ក. គេអនុញ្ញាតឲ្យអ្នកបំពេញស្វ៉ឡាត់លើផ្លូវ ដែលមានមនុស្សដើរដាស ។___

ខ. កន្លែងស្វ៉ឡាត់មិនត្រូវមិននឹងទេ ។___

គ. បើបុរសនិងនារីបំពេញស្វ៉ឡាត់លើ កន្លែងតែមួយ បុរសត្រូវងើបនិងត្រូវបំពេញស្វ៉ឡាត់ក្រោយនារី ។___

ឃ. កន្លែងដាក់ថ្ងាសពេលសាច់ដ្វាស់ត្រូវខ្ពស់ ឬទាបបួនធ្នាប់ជាងកន្លែងដាក់ម្រាមជើងនិងជង្គង់ ។___

ង. អ្នកនឹងបានរង្វាន់ស្មើគ្នាបើអ្នកបំពេញស្វ៉ឡាត់ នៅឯម៉ាស់យ៉ីឌ្ទុល គូហ្វាស់ ឬ បៃទុល មុកក៏ដ្ទាស់ ។___

៣. ចូរតម្រៀបម៉ាស់យ៉ីដ្ទខាងក្រោមនេះ តាមអត្រាស្វាវ៉ាប់ពីច្រើនទៅតិច ។

| | |
|---|---|
| ម៉ាស់យ៉ីឌ្ទុន ណាប៊ី | ១)______(ស្វាវ៉ាប់ច្រើនជាងគេ) |
| ម៉ាស់យ៉ីឌ្ទុល គូហ្វាស់ | ២)____________ |
| ម៉ាសយ៉ីដ្ទជិតខាង | ៣)____________ |



## លំហាត់ ៨

ចូរបំពេញចន្លោះទទេ ។

១. បុគ្គលណាដែលចាត់ទុកស្វ៉ឡាត់ជាអ្វីមួយធម្មតា មិនធំដុំ បុគ្គលនោះដូចបុគ្គលដែល មិនបានបរិច្ចាគ_______ ហើយសមតែទទួលរងនូវទារុណកម្មក្នុង_____ ។ (ព្រះសាស្តាﷺ)

២. ស្វ៉ឡាត់ជាភាសាអារ៉ាប់មានន័យថា ការគោរពបូជាដែលជាបទបញ្ញត្តិក្នុងសាសនាអ៊ីស្លាម ។ ការគោរពបូជាគឺការព្រមចុះចូលទាំងស្រុងចំពោះ______ ។

៣. អ្នកណាមិនបំពេញស្វ៉ឡាត់ទេ អ្នកនោះដូចអ្នក______ ព្រោះអ្នកនោះបដិសេធអល់ឡោះហ្វ ។ (គួរអាន)

៤. ប្រសិនបើអល់ឡោះហ្វ_________ស្វ៉ឡាត់អ្នក ទង្វើល្អទាំងឡាយរបស់អ្នកក៏ដូច្នោះដែរ ។ (ព្រះសាស្តាﷺ)

៥. ប្រសិនបើអ្នកបំពេញស្ម៍ឡាត់ដឹងថា អល់ឡោះហ្វទ្រង់ព្រះរាជទានព្រះមេត្តាធម៌ ព្រះអង្គមកលើរូបគេប៉ុណ្ណាខ្លះក្នុងពេលដែលគេបំពេញស្ម៍ឡាត់នោះ អ្នកនោះច្បាស់ជាមិនចង់ងើបក្បាលពី_______ ។ (អ៊ីម៉ាំអាលី صلوات الله عليه والسلام)

៦. ស្ម៍ឡាត់កម្ចាត់ភាពងងឹតពី_______ ដោយសារពន្លឺនៃ_______ ។

៧. រ៉ក់អាត់ទាំង ១៧ របស់ស្ម៍ឡាត់វ៉ាយ៉ីបប្រើពេលបំពេញតែប្រមាណ_____នាទីទេ ។ មាន_____ម៉ោងក្នុងមួយថ្ងៃ ។

៨. ចូរសរសេរសេចក្តីសំខាន់របស់ការទៀងទាត់ ក្នុងការបំពេញស្ម៍ឡាត់ ។

## លំហាត់ ៩

១. ចូរបំពេញចន្លោះទទេ ។



ក. មិនអនុញ្ញាតឲ្យបំពេញស្ម៍ឡាត់លើកន្លែង ដែល_______(របស់អ្នកដទៃ) ដោយឥតបានទទួលការអនុញ្ញាត ។

ខ. កន្លែង_________ត្រូវតែហៀរ ។ កន្លែងសម្រាប់____និង____អាចមិនតែហៀរ កុំឲ្យតែណាយ៉ីស (نجس)រាលដាលមកដល់រាងកាយ និងសំលៀកបំពាក់របស់អ្នកស្ម៍ឡាត់ ។

គ. សម្រាប់____ បំពេញស្ម៍ឡាត់នៅឯ____ប្រសើរជាងនៅឯម៉ាស់យ៉ីដ ។

ឃ. ព្រះសាស្តា ﷺ យើង មានព្រះវចនៈថា_______នឹងត្អូញប្រាប់អល់ឡោះហ្វ عزّ وجلّ បើពុំមានអ្នកណាមកស្ម៍ឡាត់ទីនោះទេ ។

ង. បើនារីនិងបុរសបំពេញស្ម៍ឡាត់ នៅលើកន្លែងតែមួយ គប្បីឲ្យមាន_____ ឬ _______នៅត្រង់ចន្លោះពួកគេ ។

ច. បំពេញស្ម៍ឡាត់នៅឯឆ្នេរសមុទ្រ ជា_______

ម៉ាស់យ៉ើឌ្ហុល ហ្ារ៉ម ៩)____________

៤. ចូរលើកឡើងនូវ ៥ កន្លែងដែលម៉ាក់រុះហ្វ៍បំពេញស្ម៍ឡាត្ហ៍ ។

## លំហាត់ ១០

១. ចូរគូសពាក្យដែលនៅឯប៉ែកខាងស្តាំ ភ្ជាប់ជាមួយអត្ថន័យរបស់វា ។

| | |
|---|---|
| ត្ហ៍ហ្វៀរ | ត្រូវសំឡែះតាមច្បាប់អ៊ីស្លាម ។ |
| មូបាស្ហ៍ | បរិសុទ្ធ ។ |
| ស្ហាប៊ីហ្ាស្ហ៍(ذبيحة) | បានមកស្របតាមច្បាប់ ។ |

២. អាប់បាស់មិត្តរបស់អ្នកមកលេងអ្នក ជាលើកដំបូង ។ ដល់ពេលស្ម៍ឡាត្ហ៍ វាបានចាប់ផ្តើមបំពេញស្ម៍ឡាត្ហ៍នៅឯកៀនបន្ទប់ទទួលភ្ញៀវ ។ វាបំពេញស្ម៍ឡាត្ហ៍ជាមួយក្រវ៉ាត់កនិងខ្សែក ។ ក្រវ៉ាត់កសាលារបស់វាធ្វើអំពីសូត្រ ហើយខ្សែកវាធ្វើអំពីមាស ។ ខ្សែក្រវ៉ាត់ខោវាធ្វើអំពីស្បែកសត្វ ហើយនៅលើបន្ទះស្លាកមានសរសេរថា

"Made in Cambodia" ។ តើស្ទ័ឡាត៉ុវាត្រូវមោឃៈឬទេ ? ចូរផ្តល់មូលហេតុបីប្រការ ។

៣. ដោយផ្អែកលើឧទាហរណ៍ខាងលើនេះដដែល ប្រសិនបើអ្នកមកលេងផ្ទះអ្នក ជាញាតិស្រីរបស់អ្នកឈ្មោះស្ទ័ប៊ីរ៉េះហ្វ (ពាក់ខ្សែកមាស ខ្សែក្រវ៉ាត់សាលាធ្វើអំពីសូត្រ និងខ្សែក្រវ៉ាត់ចង្កេះធ្វើអំពីស្បែកដែរ) ។ តើស្ទ័ឡាត៉ុរបស់នាងត្រូវមោឃៈទេ ? ហេតុអ្វី ?

៤. តើខ្សែក្រវ៉ាត់ចង្កេះធ្វើអំពីស្បែកស្ម៉ាប៊ីហ្ម៉ាស៉ុ (ذبيحة) ទេ (មកពីសត្វដែលត្រូវសំឡេះតាមច្បាប់អ៊ីស្លាម) ? ចូរពន្យល់ចម្លើយរបស់អ្នក ។